ក្រុមប្រឹក្សាធានារ៉ាប់រងអាស៊ាន (អង្គការមិនមែនរដ្ឋាភិបាលអាស៊ាន បញ្ចូលជាផ្លូវការដោយគណៈកម្មាធិការអចិន្ត្រៃអាស៊ាន លើកទី១៦ នាថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ១៩៨១)

ASEAN Insurance Training and Research Institute (AITRI)

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវខាងធានារ៉ាប់រងរបស់អាស៊ាន

ASEAN International Airports Association (AIAA)

សហាគមអាកាសយានដ្ឋានអន្តរជាតិ អាស៊ាន

ASEAN Inter-Parliamentary Organization (AIPO) អង្គការអន្តរសភាអាស៊ាន

ASEAN Investment Area (AIA)

តំបន់វិនិយោគអាស៊ាន ប្រទេសជាសមាជិកអាស៊ាន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីតំបន់វិនិយោគ អាស៊ាននៅចុងឆ្នាំ ១៩៩៨។ គោលបំណងចំបងនៃកិច្ចព្រមព្រៀងនេះ គឺបើកចំហរអោយកាន់តែទូលាយដល់ការវិនិយោគនៅក្នុងអាស៊ាន តាមរយៈការបង្កើតតម្លាភាពនិងលុបបំបាត់ការកីរិតនានាដែលរាំង ដល់ការវិនិយោគ ការបើកចំហអោយមានលំហូវិនិយោគដោយសេរីនេះ

នឹងធ្វើជាពីរដំណាក់កាល គឺនៅឆ្នាំ ២០១០ នឹងបើកចំហរ សំរាប់វិនិយោគិនអាស៊ាន និងនៅឆ្នាំ២០២០ នឹងបើកចំហរ សំរាប់វិនិយោគិនដទៃទៀត ។

ASEAN Investment Fund មូលនិធិវិនិយោគអាស៊ាន

ASEAN Iron and Steel Federation (AISF) សហព័ន្ធដែក និង ដែកថែបអាស៊ាន

ASEAN Japan Development Corporation (AHDC)
សាជីវកម្មអភិវឌ្ឍន៍អាស៊ាន-ជប៉ុន

ASEAN Japan Development Corporation(AJDC)
សាជីវកម្មអភិវឌ្ឍន៍អាស៊ាន_ជប៉ុន

ASEAN Japan Development Fund (AJDF) មូលនិធិអភិវឌ្ឍន៍អាស៊ាន_ជប៉ុន

ASEAN Japan Dialogue Partner (AJDP) ដៃគូចរចាអាស៊ាន - ជប៉ុន

ASEAN Japan Economic Council (AJDF) ក្រុមប្រឹក្សាសេដ្ឋកិច្ចអាស៊ាន_ជប៉ុន

ASEAN Joint Investment Road show (AJIR)
ទិសដៅវិនិយោគរួមរបស់អាស៊ាន នៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ាន លើកទី៣២ នៅប្រទេសសឹង្ហបូរី លោក Goh Chok Tong បានរំលឹកឡើងវិញនូវដំណើររបស់លោកក្នុងការរៀបចំក្នុងគោលបំណងផ្សព្វផ្សាយអំពីអាស៊ាន នៅក្នុងចំណោមតំបន់សេដ្ឋកិច្ចសំខាន់ៗដូចជានៅអាមេរិកខាងជើង អឺរ៉ុប និង អាស៊ីខាងកើត ។

ASEAN Joint Venture Project(s) (AJVP) គំរោងសហគ្រាសចំរុះអាស៊ាន

ASEAN Labour Information Network (ALINE)
បណ្តាញពត៌មានស្តីពីពលកម្មអាស៊ាន

ASEAN Labour Ministers Meeting (ALMM)
កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីក្រសួងការងារអាស៊ាន

ASEAN Latin America Economic Cooperation (ALAEC)
សហប្រតិបត្តិការ សេដ្ឋកិច្ចអាមេរិក ឡាទិន អាស៊ាន

ASEAN Law Association (ALA)
សមាគមច្បាប់អាស៊ាន (អង្គការមិនមែនរដ្ឋាភិបាលអាស៊ាន បញ្ចូលជាផ្លូវការដោយគណៈកម្មាធិការអចិន្ត្រៃយ៍ អាស៊ាន លើកទី១៦ នាថ្ងៃទី ២១ ខែមេសា ឆ្នាំ១៩៨៣)

ASEAN Livestock Business Club (ALBC)
ក្លឹបពាណិជ្ជកម្ម(ធុរកិច្ច)ចិញ្ចឹមសត្វអាស៊ាន

ASEAN London Committee (ALC) គណៈកម្មាធិការអាស៊ាន នៅទីក្រុងឡុងដុន

ASEAN Manufacturing Companies ក្រុមហ៊ុនផលិតផលរបស់អាស៊ាន

ASEAN Manufacturing Sector ផ្នែកផលិតកម្មរបស់អាស៊ាន

ASEAN Marine Pollution Control Centre (AMPCC)
មជ្ឈមណ្ឌលត្រួតពិនិត្យ ភាពកខ្វក់សមុទ្រអាស៊ាន

ASEAN Materials Technology Information Centre (AMTIC)
មជ្ឈមណ្ឌលសំភារៈពត៌មានវិជ្ជា អាស៊ាន

ASEAN Meeting with Dialogue Partners (AMDP)
កិច្ចប្រជុំអាស៊ានជាមួយ ដៃគូសន្ទនា អាស៊ានមានដៃគូរជាមួយបណ្ដាប្រទេស និងអង្គការអន្តរជាតិមួយចំនួនដែលបានសហការជាមួយគ្នាយ៉ាងជិតស្និទ្ធដូចជា Australia, Canada, the EU, Japan, Republic of Korea, New Zealand, Russia, USA, UNDP, China និង India ។

ASEAN Member Country (AMC) ប្រទេសសមាជិកអាស៊ាន

ASEAN Member States (AMS) រដ្ឋដែលជាសមាជិករបស់អាស៊ាន

ASEAN Microeconomic Outlook (AMO) ទស្សនវិស័យមីក្រូសេដ្ឋកិច្ចអាស៊ាន

ASEAN Millennium Year ឆ្នាំសហស្សវត្សអាស៊ាន

ASEAN Minerals Plan Cooperation (AMPC)
សហប្រតិបត្តិការផែនការ រ៉ែ អាស៊ាន

ASEAN Mining Association (AMA) សមាគមអាជីវកម្មរ៉ែអាស៊ាន

ASEAN Ministerial Meeting (AMM)
កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន
គឺជាកិច្ចប្រជុំប្រចាំឆ្នាំរបស់រដ្ឋមន្ត្រីការបរទេសអាស៊ាន ដែលបានបង្កើតឡើងដោយសេចក្តីថ្លែងការណ៍នាទីក្រុង បាងកកនាឆ្នាំ ១៩៦៧ ។ កិច្ចប្រជុំនេះមានភារកិច្ចទទួលខុសត្រូវចំពោះការរៀបចំ គោលនយោបាយ និង ការសំរបសំរួលសកម្មភាពអាស៊ាន ។ កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ានរាយការណ៍រួមគ្នា ជូនទៅប្រមុខរដ្ឋាភិបាលអាស៊ាននៅក្នុងសន្និសីទកំពូលអាស៊ាន ។

ASEAN Ministerial Meeting on the Environment (AMME)
កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី អាស៊ាន ស្តីពីបរិស្ថាន

ASEAN Ministerial Meeting on Youth (AMMY)
កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី អាស៊ាន ផ្នែកយុវជន

ASEAN Ministerial Meeting/Post Ministerial Conference (AMM/PMC)
កិច្ចប្រជុំរដ្ឋមន្ត្រី អាស៊ាន សន្និសីទរវាងរដ្ឋមន្ត្រីការបរទេសអាស៊ាន និង ដៃគូសន្ទនារបស់អាស៊ានក្រោយ AMM

ASEAN Ministers for Agriculture and Forestry (AMAF)
រដ្ឋមន្ត្រី អាស៊ាន សំរាប់កសិកម្ម និង រុក្ខាប្រមាញ់

ASEAN Ministers of Energy Meeting (AMEM)
កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានផ្នែកថាមពល

ASEAN Ministers of Environment (AME) រដ្ឋមន្ត្រីអាស៊ាន សំរាប់បរិស្ថាន

ASEAN Ministers on Science and Technology (AMST)

រដ្ឋមន្ត្រីអាស៊ាន សំរាប់វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា

ASEAN Ministers Responsible for Information (AMRI)

រដ្ឋមន្ត្រីទទួលបន្ទុកពត៌មានអាស៊ាន

ASEAN Mission Administered Fund (MAF) មូលនិធិចាត់ចែងបេសកកម្មអាស៊ាន

ASEAN Monetary Fund មូលនិធិរូបិយវត្ថុអាស៊ាន

ASEAN Motion Picture Producers association (AMPPA)

សមាគមផលិតករ ភាពយន្តអាស៊ាន

ASEAN Multi-Media Centre មជ្ឈមណ្ឌលប្រព័ន្ធពត៌មានចំរុះអាស៊ាន

ASEAN Music Industry Association (AMIA)

សមាគមឧស្សាហកម្មតន្ត្រីអាស៊ាន

(អង្គការមិនមែនរដ្ឋាភិបាលអាស៊ានបញ្ចូលជាផ្លូវការដោយ

គណៈកម្មាធិការអចិន្ត្រៃអាស៊ានលើកទី ១៤ នាថ្ងៃទី ២១ ខែឧសភា ឆ្នាំ១៩៨៧)

ASEAN National Co-ordinating Agency of Philippines (ANCAP)

ទីភ្នាក់ងារ សំរបសំរួលជាតិអាស៊ានរបស់ហ្វីលីពីន

ASEAN National Secretariat (ANS)

រដ្ឋលេខាធិការដ្ឋានជាតិអាស៊ាន

នៅតាមបណ្តាប្រទេសអាស៊ាននីមួយៗចាំបាច់ត្រូវតែមាន

ANS ប្រចាំនៅក្នុងក្រសួងការបរទេស របស់ខ្លួន។

ANS មានភារកិច្ចរៀបចំ និងអនុវត្តនូវរាល់សកម្មភាពកិច្ចការ

របស់អាស៊ានទៅតាមកំរិតថ្នាក់របស់ប្រទេសខ្លួនហើយ ប្រធាន ANS មានឋានៈជាអគ្គនាយក(General Director)

ASEAN National Tourism Organizations (ANTOs)
អង្គការទេសចរណ៍ជាតិ អាស៊ាន

ASEAN Natural Disasters Information Network (ANDIN)
បណ្តាញពត៌មាន អាស៊ាន ស្តីពីគ្រោះធម្មជាតិ

ASEAN Network for Environmental Management (ASNEM)
បណ្តាញការងារអាស៊ានសំរាប់ ការគ្រប់គ្រងបរិស្ថាន

ASEAN Network for Women in Skills Training
បណ្តាញការងារ អាស៊ាន សំរាប់ស្ត្រី ក្នុងការបណ្តុះបណ្តាលជំនាញ

ASEAN Network of Development Education Centres (ANDEC)
បណ្តាញការងារ អាស៊ាននៃមជ្ឈមណ្ឌលអភិវឌ្ឍន៍ អប់រំ

ASEAN Neurological Society (ANS)
អ្នកជំនាញសង្គមសិក្សាខាងសសៃប្រសាទ អាស៊ាន

ASEAN New Policy on North Korea (ANPNK)
គោលនយោបាយថ្មីរបស់ អាស៊ាន ស្តីពីកូរ៉េខាងជើង

ASEAN New Zealand Afforestation Project (ANZAP)
គំរោងដាំដើមឈើជាថ្មី របស់អាស៊ាន-នូវែលហ្សេឡង់

ASEAN New Zealand Economic Cooperation (ANZEC)
សហប្រតិបត្តិការ សេដ្ឋកិច្ចរវាងអាស៊ាន និង នូវែលហ្សេឡង់

ASEAN New Zealand Joint Management Committee (ANZJMC)
គណៈកម្មាធិការគ្រប់គ្រងចំរុះរវាងអាស៊ាន និង នូវែលហ្សេឡង់

ASEAN Newly Industrialized Economies (ANIE)
សេដ្ឋកិច្ចឧស្សាហកម្មថ្មី របស់អាស៊ាន

ASEAN News Exchange (ANEX)
ការផ្លាស់ប្តូរពត៌មានអាស៊ាន (មានទីតាំងនៅ កូឡាឡាំពួរ)

ASEAN Occupational Safety and Health Network (AOSHNET)
បណ្តាញការងារសុខភាព និងសុវត្ថិភាពការងាររបស់អាស៊ាន

ASEAN Optical Fibre Submarine Cable Network (AOFSCN)
បណ្តាញការងារទំនាក់ទំនងខ្សែកាបរុករកនៅក្រោមបាតសមុទ្រ

ASEAN Orthopedic Association (AOA)
សមាគម អ្នកជំនាញវិជ្ជាពេទ្យឆ្អឹងឆ្អែង ផ្នែកអាស៊ាន

ASEAN Ottawa Committee (AOC) គណៈកម្មាធិការអាស៊ាននៅទីក្រុងអូតាវ៉ា

ASEAN Pacific Cooperationon Human Resource Development (APC-HRD)
សហប្រតិបត្តិការ អាស៊ាន-ប៉ាស៊ីហ្វិកដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស

ASEAN Pacific Cooperation Programme (APCP)
កម្មវិធីសហប្រតិបត្តិការ អាស៊ាន-ប៉ាស៊ីហ្វិក

ASEAN Paris Committee (APC) គណៈកម្មាធិការអាស៊ាន នៅទីក្រុងប៉ារីស

ASEAN Pediatric Federation (APF)
សហព័ន្ធអ្នកជំនាញវិជ្ជាពេទ្យកុមារ ផ្នែកអាស៊ាន

ASEAN Pepper Business Club (APBC)
ក្លឹបពាណិជ្ជកម្ម(ធុរកិច្ច)ផ្នែកម្ទេសម្រេចអាស៊ាន

ASEAN Petroleum Security (APS) សន្តិសុខប្រេងឥន្ធនៈរបស់អាស៊ាន

ASEAN Petroleum Security Agreement (APSA) កិច្ចព្រមព្រៀងជានាសន្តិសុខ
ប្រេងឥន្ធនៈអាស៊ាន (ចុះហត្ថលេខានៅទីក្រុងម៉ានីលនៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ១៩៨៦)

ASEAN Petroleum Security Reserve (APSR) ការបំរុងសន្តិសុខប្រេងឥន្ធនៈ
អាស៊ាន

ASEAN Plan of Action Drug Abuse Control ផែនការសកម្មភាពត្រួតពិនិត្យ
រំលោភលើការប្រើប្រាស់គ្រឿងញៀន

ASEAN Plan of Action for Children ផែនការសកម្មភាពសំរាប់កុមាររបស់អាស៊ាន

ASEAN Plan of Action for Energy Cooperation (APAEC)
ផែនការសកម្មភាពសំរាប់កិច្ចសហប្រតិបត្តិការថាមពលរបស់អាស៊ាន

ASEAN Plan of Action on Social Safety Nets
ផែនការសកម្មភាពស្តីពីបណ្តាញទ្រទ្រង់សុវត្ថិភាពសង្គម អាស៊ាន

ASEAN Plant Pest Free Zone (APPFZ)
តំបន់ហាមឃាត់មិនអោយមាននូវសត្វចង្រៃបំផ្លាញដើមឈើរបស់អាស៊ាន

ASEAN Plant Quarantine Training Institute (APNTI)
វិទ្យាស្ថានអាស៊ានផ្នែកបណ្តុះបណ្តាលអំពីការដាក់អោយនៅដាច់ពីគ្នានៃដំណាំ

ASEAN Plus Three (APT) អាស៊ានបូកបី (ប្រទេស ចិន. ជប៉ុន, កូរ៉េខាងត្បូង)

ASEAN Plus Three Plus Two (APTPT)
អាស៊ានបូកបីបូកពីរ Asean + ជប៉ុន + ចិន + កូរ៉េខាងត្បូង (៣) + អូស្រ្តាលី + ណូវែលហ្សេឡង់ (២)

ASEAN Plywood Federation (APF)
សហព័ន្ធក្តារបន្ទះអាស៊ាន (អង្គការមិនមែន រដ្ឋាភិបាល បញ្ចូលដោយគណៈកម្មាធិការអចិន្ត្រៃយ៍លើកទី២ របស់អាស៊ាន នៅថ្ងៃទី ០៥ ខែមិនា ឆ្នាំ ១៩៨៧)

ASEAN Political and Security Co-operation
សហប្រតិបត្តិការសន្តិសុខ និងនយោបាយរបស់អាស៊ាន

ASEAN Population Programme Heads (APPH)
មេដឹកនាំកម្មវិធីប្រជាជន អាស៊ាន

ASEAN Population Co-ordination Unit (APCU)
អង្គភាពសំរបសំរួលផ្នែក ប្រជាជនអាស៊ាន

ASEAN Population Programme (APP) កម្មវិធីប្រជាជនអាស៊ាន

បណ្ណាល័យ ហ៊ុន សែន HUN SEN LIBRARY R.U.P.P. សាកលវិទ្យាល័យភូមិន្ទភ្នំពេញ



ASEAN Port Authorities Association (APAA)
សមាគមអជ្ញាធរកំពុងផែអាស៊ាន (អង្គការមិនមែនរដ្ឋាភិបាលអាស៊ាន បញ្ចូលជាផ្លូវការដោយ គណៈកម្មាធិការអចិន្ត្រៃយ៍អាស៊ាន នៅខែកញ្ញ ឆ្នាំ១៩៨៣)

ASEAN Post Harvest Exchange Regional Information Network Project
គំរោងផ្លាស់ប្តូរបណ្តាញពត៏មានក្នុងតំបន់ក្រោយពេលប្រមូលផល របស់អាស៊ាន

ASEAN Post-Ministerial Conference (ASEAN PMC) សន្និសីទថ្នាក់រដ្ឋមន្ត្រីអាស៊ាន ជាដៃគូសន្ទនា (ជាសន្និសីទដែលគេរៀបចំឡើងក្រោយការប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន)

ASEAN Post-Production Information Exchange (APEX)
ការផ្លាស់ប្តូរពត៏មាន ក្រោយផលិតកម្មអាស៊ាន
(គំរោងត្រូវបានរៀបចំឡើងដោយ COFAF អនុគណៈកម្មាធិការផ្នែកប្រើប្រាស់ស្បៀងនៅ ខែតុលា ឆ្នាំ១៩៨៥)

ASEAN Poultry Disease Research and Training Centre (APDRTC)
មជ្ឈមណ្ឌលហ្វឹកហ្វឺន និង ស្រាវជ្រាវផ្នែកជំងឺបសុបក្សីអាស៊ាន (រៀបចំឡើងនៅ Ipoh ដោយមានជំនួយពីជប៉ុន ហើយត្រូវបានបើកជាផ្លូវការនៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៨៩)

ASEAN Power Grid (APG) បណ្តាញចែកចាយថាមពលរបស់អាស៊ាន

ASEAN Preferential Trading Arrangement (APTA)
ការរៀបចំពាណិជ្ជកម្មស្បៀងរបស់អាស៊ាន

ASEAN Private Sector (APS) វិស័យឯកជនអាស៊ាន

HUN SEN LIBRARY



ASEAN Programme on Industrial Relations and Labour Studies (APIRLAS)
កម្មវិធីអាស៊ាន ស្តីពីការទំនាក់ទំនងឧស្សាហកម្ម និង ការសិក្សាផ្នែកពលកម្ម

ASEAN Promotion Centre (APC) មជ្ឈមណ្ឌលផ្សព្វផ្សាយពាណិជ្ជកម្មអាស៊ាន
មជ្ឈមណ្ឌលនេះបានបង្កើតឡើង ដើម្បីលើកទឹកចិត្តការនាំចេញរបស់អាស៊ាននៅប្រទេសជប៉ុន ដែលត្រូវបានធ្វើសារជាថ្មីឡើងវិញដោយអាស៊ាន និង ជប៉ុនសំរាប់រយៈពេល ៥ឆ្នាំទៀត ដោយគិតចាប់ពីខែ ឧសភា ឆ្នាំ១៩៨៧ ដល់ខែ ឧសភា ឆ្នាំ១៩៩២

ASEAN Promotional Chapters for Tourism (APCTs)
សាខាផ្សព្វផ្សាយពាណិជ្ជកម្មសំរាប់ទេសចរណ៍អាស៊ាន

ASEAN Pulp and Paper Industry Club (APPIC)
ក្លឹបឧស្សាហកម្មក្រដាស និង ម្សៅក្រដាសអាស៊ាន

ASEAN Railway General Managers Conference (ARGMC)
សន្និសីទនៃអគ្គនាយកផ្លូវដែកអាស៊ាន

ASEAN Regional Aids Information and Reference Network
ពត៌មានជំនួយនិងបណ្តាញទំនាក់ទំនងនៅក្នុងតំបន់អាសាន

ASEAN Regional Centre for Biodiversity Conservation (ARCBC)
មជ្ឈមណ្ឌលសំរាប់អភិរក្សជីវចំរុះនៅតំបន់អាស៊ាន

ASEAN Regional Development Center for Mineral Resources (ARDCMR)
មជ្ឈមណ្ឌលអភិវឌ្ឍន៍តំបន់អាស៊ានសំរាប់ធនធានរ៉ែ

ASEAN Regional Forum (ARF) វេទិកាតំបន់អាស៊ាន
គឺជាវេទិកានៃការប្រជុំកិរិតរដ្ឋមន្ត្រីការបរទេសអាស៊ាន និង រដ្ឋមន្ត្រីការបរទេស ឬ តំណាងនៃប្រទេសចូលរួម (participating countries) នៅក្នុងវេទិកាអាស៊ានទាំងអស់ ។

វេទិកានេះបានផ្តួចផ្តើម ដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន ហើយបានប្រជុំលើកទីមួយនៅខែ កក្កដា ឆ្នាំ ១៩៩៤។ វេទិកាតំបន់អាស៊ានមានគោលបំណងកសាងនូវទំនុកចិត្តរវាងប្រទេសសមាជិកអាស៊ាន និង ប្រទេសដទៃទៀតនៅអាស៊ីប៉ាស៊ីហ្វិក ដើម្បីពង្រឹងស្ថេរភាព សន្តិភាព និង សន្តិសុខនៅក្នុងតំបន់ទាំងមូល ។ ដើម្បីសំរេចបាននូវបំណងនេះ វេទិកាតំបន់អាស៊ានបាននឹងកំពុងអនុវត្តកម្មវិធីរបស់ខ្លួនដែលចែកចេញជាបីដំណាក់កាលគឺ :

១.វិធានការជំរុញការស្ថាបនាទំនុកចិត្តរវាងប្រទេសចូលរួម (Promotion of Confidence-Building Measures),

២. បង្កើតយន្តការការពារការទូត (Development of Preventive Diplomacy Mechanisms), និង

៣. បង្កើតយន្តការដំណោះស្រាយជំលោះ (Development of Conflict-Resolution Mechanisms) ។

ASEAN Regional Forum Inter-Sectional Meeting on Search and Rescue
វេទិកា កិច្ចប្រជុំរវាងការផ្នែកផ្សេ និងការជួយសង្គ្រោះនៅតំបន់អាស៊ាន

ASEAN Regional Forum Senior Officials Meeting (ARFSOM)
វេទិកាកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់នៅ តំបន់អាស៊ាន

ASEAN Regional Fund for Trademark and Patent
មូលនិធិផ្លាកសញ្ញា និងប្រកាសនីយប័ត្រតក្កកម្មនៅតំបន់អាស៊ាន

ASEAN Regional Research and Training Centre
មជ្ឈមណ្ឌលស្រាវជ្រាវ និងការបណ្តុះបណ្តាល នៅតំបន់អាស៊ាន

ASEAN Regional Specialized Meteorological Centre (ARSMC)
មជ្ឈមណ្ឌលជំនាញខាងឧតុនិយមនៅតំបន់អាស៊ាន

ASEAN Regional Studies Promotion Programme (ARSPP)
កម្មវិធីលើកទឹកចិត្ត ការសិក្សាអំពីតំបន់អាស៊ាន
កម្មវិធីរយៈពេល ៥ ឆ្នាំ ដើម្បីជំរុញការយល់ដឹងកាន់តែច្រើន
របស់ជប៉ុន អំពីអាស៊ាន ដែលធ្វើឡើងនូវឆ្នាំ ១៩៨២និងហិរញ្ញប្បទាន
ដោយជប៉ុន ។ ការសរុបជាផ្លូវការត្រូវបានធ្វើ ឡើងនៅតូក្យូពីថ្ងៃទី
០៣ ដល់ថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ១៩៨៧ ។

ASEAN Regional Trademark ផ្លាកសញ្ញាពាណិជ្ជកម្មតំបន់អាស៊ាន

ASEAN Regional Trademark and Patent Filing System
ផ្លាកសញ្ញាពានិជ្ជកម្ម និង ប្រព័ន្ធបំពេញសំនុំបែបបទ
ប្រកាសនីយប័ត្រតក្កកម្មនៅតំបន់អាស៊ាន

ASEAN Reinsurance Corporation (ARC)
សាជីវកម្មធានារ៉ាប់រងជាថ្មីរបស់អាស៊ាន

ASEAN Routine Weather Report from Aircraft in Flight Programme (AIREP)
របាយការណ៍ស្តីពីអាកាសធាតុជាប្រចាំរបស់អាស៊ាន ដែលបាន
មកពីកម្មវិធីយន្តហោះកំពុងហោះហើរ

ASEAN Rural Development and Poverty Eradication
ការអភិវឌ្ឍន៍ជនបទ និងការលុបបំបាត់ចោលនូវភាពក្រីក្ររបស់អាស៊ាន

ASEAN Rural Youth Development Center (ARYDEC)
មជ្ឈមណ្ឌលអភិវឌ្ឍន៍ យុវជន ជនបទអាស៊ាន

ASEAN Scholarship Programme for Applied Tropical Medicine and Public Health (ASPATMPH)
កម្មវិធីអាហារូបករណ៍របស់អាស៊ាន សំរាប់វេជ្ជសាស្រ្តតំបន់ត្រូពិច និង
សុខភាពសាធារណៈ

ASEAN Schools Sport Council (ASSC) ក្រុមប្រឹក្សាកីឡានៅតាមសាលាអាស៊ាន

ASEAN Science and Technology Human Resource Program
កម្មវិធី វិទ្យាសាស្ត្រ បច្ចេកវិជ្ជា និងធនធានមនុស្សរបស់អាស៊ាន

ASEAN Science Fund (ASF) មូលនិធិវិទ្យាសាស្ត្រអាស៊ាន

ASEAN Secretariat

លេខាធិការដ្ឋានអាស៊ាន

(មានទីតាំងនៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី)

ប្រទេសសមាជិកអាស៊ាន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការបង្កើតលេខាធិការដ្ឋានអាស៊ាន នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ១៩៧៦ នៅទីក្រុង បាលីនៃប្រទេសឥណ្ឌូនេស៊ី ។ លេខាធិការដ្ឋានអាស៊ាន កាលដើមដំបូងបានដើរតួនាទីជាចំណុចប្រមូលផ្តុំ និង ស្ថាប័នសំរបសំរួល នៃបណ្តាកិច្ចការដែលពាក់ព័ន្ធនឹងប្រទេសជាសមាជិកទាំងអស់។ ក៏ប៉ុន្តែចាប់ពីពេលបដិសន្ធិរហូតមកដល់ពេលបច្ចុប្បន្ន អាស៊ានបាន ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរបស់ខ្លួនលើគ្រប់វិស័យដែលតំរូវអោយពង្រឹងនូវ តួនាទី និង សមត្ថកិច្ចរបស់លេខាធិការដ្ឋានអាស៊ាន។ នៅក្នុងបរិបទនេះ ប្រទេសជាសមាជិកអាស៊ានបានធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងស្តីពីការបង្កើតលេខាធិការដ្ឋានអាស៊ានចំនួនបួនលើករួចមកហើយ គឺនៅឆ្នាំ ១៩៧៩ ១៩៨៣ ១៩៨៥ និង ១៩៩២ ដែលបានប្រែក្លាយលេខាធិការដ្ឋានអាស៊ានអោយទៅជាសេនាធិការមួយរឹងមាំ ទាំងផ្នែកបរិមាណ និងគុណភាព ។

ASEAN Senior Finance Officials Meeting (ASFOM)
កិច្ចប្រជុំមន្ត្រីហិរញ្ញវត្ថុជាន់ខ្ពស់របស់អាស៊ាន

ASEAN Senior Law Officials Meeting (ASLOM)
កិច្ចប្រជុំមន្ត្រីច្បាប់ជាន់ខ្ពស់របស់អាស៊ាន

ASEAN Senior Officials Meeting (ASOM) កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់របស់អាស៊ាន

ASEAN Senior Officials on Drug Matters (ASODM)
ឧត្តមមន្ត្រីអាស៊ានទទួល បន្ទុកបញ្ហាគ្រឿងញៀន

ASEAN Senior Officials on Environment (ASOEN)
ឧត្តមមន្ត្រីអាស៊ានទទួលបន្ទុកបរិស្ថាន

ASEAN Senior Trade Officials (ASTO) ឧត្តមមន្ត្រីពាណិជ្ជកម្មអាស៊ាន

ASEAN Small and Medium Industries (ASMIC)
ឧស្សាហកម្មធុនតូច និង មធ្យមអាស៊ាន

ASEAN Small-Scale Agro-Engineering Post-Harvest Technology Project (AGRORECH)
គំរោងបច្ចេកវិទ្យាកសិវិស្វកម្មក្រោយការ ប្រមូលផលខ្នាតតូច

ASEAN Social Development Fund (ASDF) មូលនិធិអភិវឌ្ឍន៍សង្គមរបស់អាស៊ាន

ASEAN Soda Ash Company (ASAC) ក្រុមហ៊ុនសូដាអាស់របស់អាស៊ាន

ASEAN Special Visit Scheme (ASVS)
គ្រោងការណ៍ទស្សនកិច្ចពិសេសរបស់អាស៊ាន

ASEAN Specialized Meteorological Center (ASMC)
មជ្ឈមណ្ឌលឧត្តុនិយមដែលពិសេសរបស់អាស៊ាន

ASEAN Standing Committee (ASC)
គណៈកម្មាធិការអចិន្ត្រៃអាស៊ាន គឺជាគណៈកម្មាធិការមួយ ដែលមានសមាសភាពចូលរួមដោយ អគ្គនាយកអាស៊ានពីប្រទេសជាសមាជិកអាស៊ាន ។ ជាទូទៅអាស៊ានជួបប្រជុំម្តងហើយធ្វើរបាយការណ៍អំពីការងាររបស់ខ្លួនជូនរដ្ឋមន្ត្រីការបរទេសអាស៊ាន ។

ASEAN State Trading Organization (STO) អង្គការពាណិជ្ជកម្មរដ្ឋរបស់អាស៊ាន

ASEAN Steel Community (ASC)
សហគមន៍ដែកថែបអាស៊ាន
(ក្រៅពីនេះ នៅមានក្លឹបដែកថែបអាស៊ានថែមទៀត)

ASEAN Strategic Plan of Action on the Environment (ASPEN)
ផែនការសកម្មភាពយុទ្ធសាស្ត្រអាស៊ាន ស្តីពីបរិស្ថាន

ASEAN Sub-Committee on Civil Aviation and Related Services (ASCCARS)
អនុគណៈកម្មាធិការ អាស៊ាន ស្តីពី អាកាសចរណ៍ស៊ីវិល និង សេវាកម្មដែលពាក់ព័ន្ធ

ASEAN Sub-Committee on Food, Science and Technology (SCFST)
អនុគណៈកម្មាធិការអាស៊ាន ស្តីពីស្បៀងអាហារវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា

ASEAN Sub-Committee on Health and Nutrition (ASCH & N)
អនុគណៈកម្មាធិការ អាស៊ាន ស្តីពី សុខភាព និង ចំណីអាហារអាស៊ាន

ASEAN Sub-Committee on Meteorology and Geography (SCMG)
អនុគណៈកម្មាធិការអាស៊ាន ស្តីពីឧត្តុនិយមវិទ្យា និង ភូមិវិទ្យា

ASEAN Sub-Committee on Science, Technology Infrastructure, Resources and Development (SCIRD)
អនុគណៈកម្មាធិការ អាស៊ាន ស្តីពីវិទ្យាសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យា ធនធាន និង ការអភិវឌ្ឍន៍

ASEAN Sub-Committee on Tourism (ASCOT)
អនុគណៈកម្មាធិការអាស៊ាន ស្តីពីទេសចរណ៍

ASEAN Sub-Committee on Youth (ASY)
អនុគណៈកម្មាធិការអាស៊ាន ស្តីពី យុវជន

ASEAN Sugar Business Club (ASBC) ក្លឹបពាណិជ្ជកម្ម(ធុរកិច្ច)ស្ករអាស៊ាន

ASEAN Summit ជំនួបកំពូលអាស៊ាន

ASEAN Surveillance Coordinating Unit (ASCU)
ក្រុមសំរបសំរួលដើម្បីឃ្លាំមើលរបស់ អាស៊ាន

ASEAN Surveillance Process (ASP) ដំណើរការឃ្លាំមើលរបស់អាស៊ាន

ASEAN Swap Arrangement (ASA) គំរោងដោះដូរអាស៊ាន

ASEAN Task Force on AIDS (ATFOA) ក្រុមការងារស្តីពីជំងឺអេដស៍របស់អាស៊ាន

ASEAN Tax Training Institute (ATTI) វិទ្យាស្ថានបណ្តុះបណ្តាលខាងពន្ធដាអាស៊ាន

ASEAN Technology Development Center (ATDC)
មជ្ឈមណ្ឌលអភិវឌ្ឍន៍ បច្ចេកវិទ្យាអាស៊ាន

ASEAN Technology Information System (ASTIS)
ប្រព័ន្ធពត៏មានបច្ចេកវិទ្យាអាស៊ាន

ASEAN Telecommunication Regulator's Council (ATRC)
ក្រុមប្រឹក្សាអ្នកត្រួតត្រា(និយតករ)បណ្តាញទូរស័ព្ទអាស៊ាន

ASEAN Timber Technology Centre (ATTC)
មជ្ឈមណ្ឌលបច្ចេកវិទ្យាព្រៃឈើ អាស៊ាន (ស្ថិតនៅទីក្រុងកូឡាឡាំពួរ)

ASEAN Tokyo Committee (ATC) គណៈកម្មាធិការអាស៊ាន នៅទីក្រុង តូក្យូ

ASEAN Tourism Association (ASENTA) សមាគមទេសចរណ៍អាស៊ាន

ASEAN Tourism Forum (ATF) វេទិកាទេសចរណ៍អាស៊ាន

ASEAN Tourism Investment Guide មគ្គុទេសវិនិយោគខាងទេសចរណ៍អាស៊ាន

ASEAN Tourism Training Centres មជ្ឈមណ្ឌលហ្វឹកហ្វឺនខាងទេសចរណ៍អាស៊ាន

ASEAN Tourist Information Centre (ATIC)
មជ្ឈមណ្ឌលពត៏មានទេសចរណ៍ អាស៊ាន
(ត្រូវបានសំរេចក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីសេដ្ឋកិច្ច អាស៊ានលើកទី ១៨ ខែសីហា ឆ្នាំ ១៩៨៦ ថាត្រូវស្ថិតនៅ ទីក្រុងកូឡាឡាំពួរ)

ASEAN Tours and Travel Association (ASEANITA)
សមាគមការធ្វើដំណើរ និង ទេសចរណ៍អាស៊ាន

ASEAN Trade Union Council (ATUC) ក្រុមប្រឹក្សាសហជីពអាស៊ាន

ASEAN-Trading and Investment Corporation (ATIC)
សាជីវកម្ម វិនិយោគទុន និងពាណិជ្ជកម្មអាស៊ាន

ASEAN-Training and Information Centre for the Improvement of Working Conditions and Environment Projects (PIACT)
មជ្ឈមណ្ឌលពត៌មាន និងហ្វឹកហ្វឺនសំរាប់កែលំអ លក្ខខណ្ឌការងារ និងគំរោង បរិស្ថាន (ប្រធានបទនេះ ត្រូវបានចាប់អារម្មណ៍នៅក្នុងសេចក្តីថ្លែងការណ៍រួមលើកទី ៧ របស់រដ្ឋមន្ត្រីការងារអាស៊ាន)

ASEAN-Training Centre (ATC) មជ្ឈមណ្ឌលហ្វឹកហ្វឺនអាស៊ាន

ASEAN-Training Centre for Primary Health Care (ATC/PHC)
មជ្ឈមណ្ឌលហ្វឹកហ្វឺនអាស៊ាន សំរាប់ការថែរក្សា សុខភាពបឋម

ASEAN Transport Ministers (ATM) រដ្ឋមន្ត្រីខាងដឹកជញ្ជូនរបស់អាស៊ាន

ASEAN- Transportation and Communication Study (ATCS)
ការសិក្សាស្តីពីការដឹកជញ្ជូន និងគមនាគមន៍អាស៊ាន

ASEAN Troika
ត្រីភាគីអាស៊ាន មានប្រទេសបីគឺ ឥណ្ឌូណេស៊ី ហ្វីលីពីន និងថៃឡង់ដ៍ ដែលរួមគ្នាជាតំណាងអាស៊ាន ហើយមានបំណងជួយជ្រោមជ្រែងដល់ដំណោះស្រាយវិបត្តិនយោបាយនៅប្រទេស កម្ពុជា។

ASEAN-UNDP Sub- Regional Program (ASP)
កម្មវិធីអនុតំបន់របស់អាស៊ាន_យូអិនឌីភី (កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ)

ASEAN UNDP Sub-Regional Programme for the fifth Cycle (ASP-5)
កម្មវិធីអនុតំបន់របស់អាស៊ាន យូអិនឌីភី សំរាប់បរិបទលើកទី៥

ASEAN University Network (AUN) បណ្ដាញសកលវិទ្យាល័យអាស៊ាន

ASEAN University Sports Council (AUSC)
ក្រុមប្រឹក្សាកីឡាតាម សកលវិទ្យាល័យអាស៊ាន
(អង្គការមិនមែនរដ្ឋាភិបាល អាស៊ាន បញ្ចូលជាផ្លូវការដោយ
គណៈកម្មាធិការ អចិន្ត្រៃយ៍ លើកទី ១៥ របស់អាស៊ាន នៅថ្ងៃទី ៥
ខែធ្នូ ឆ្នាំ ១៩៨១)

ASEAN-US Business Council (AUSBC)
ក្រុមប្រឹក្សាពាណិជ្ជកម្ម(ធុរកិច្ច)អាស៊ាន_សហរដ្ឋអាមេរិក

ASEAN-US Co-operative Programme on Marine Sciences (AUCPMS)
កម្មវិធីសហប្រតិបត្តិការអាស៊ាន_ សហរដ្ឋអាមេរិក
ស្ដីពីវិទ្យាសាស្ត្រសមុទ្រ

ASEAN Valuers Association (AVA)
សមាគមអ្នកវាយតំលៃអាស៊ាន (អង្គការមិនមែនរដ្ឋាភិបាលអាស៊ាន
បញ្ចូលជាផ្លូវការដោយ គណៈកម្មាធិការអចិន្ត្រៃយ៍អាស៊ាន នៅថ្ងៃទី ២១
ខែមេសា ឆ្នាំ ១៩៨៣)

ASEAN Vision 2020 (AV2020) ទស្សនៈវិស័យអាស៊ានឆ្នាំ ២០២០

ASEAN Washington Committee (AWC) គណៈកម្មាធិការអាស៊ាន នៅទីក្រុង
វ៉ាស៊ីនតោន

ASEAN Women's Council (AWC) ក្រុមប្រឹក្សានារីអាស៊ាន

ASEAN Women's Fund (AWF) មូលនិធិរបស់នារីអាស៊ាន

ASEAN Women's Programme (AWP) កម្មវិធីនារីអាស៊ាន

ASEAN Work Programme on Skills Training for out of School Youth
កម្មវិធីការងាររបស់អាស៊ាន ស្តីពីការបណ្តុះបណ្តាលសំរាប់យុវជនមិនបានចូលសាលា

ASEAN Working Group on ASEAN Seas and Marine Environment (AWGASME)
ក្រុមការងារអាស៊ាន ស្តីពីសមុទ្រ និងបរិស្ថានសមុទ្រអាស៊ាន

ASEAN Working Group on Customs Matters (AWGCM)
ក្រុមការងារអាស៊ានស្តីពីបញ្ហាគយ

ASEAN Working Group on Environmental Economics (AWGEE)
ក្រុមការងារអាស៊ាន ស្តីពីវិទ្យាសាស្ត្រ សេដ្ឋកិច្ចបរិស្ថាន

ASEAN Working Group on Environmental Information, Public Awareness & Education (AWGEIPE)
ក្រុមការងារ អាស៊ានស្តីពីពត៌មានបរិស្ថាន ចំណេះដឹងសាធារណៈ និងការអប់រំ

ASEAN Working Group on Environmental Management (AWGEM)
ក្រុមការងារអាស៊ានស្តីពី ការគ្រប់គ្រង បរិស្ថាន

ASEAN Working Group on Marine Sciences (AWGMS)
ក្រុមការងារអាស៊ានស្តីពីវិទ្យាសាស្ត្រខាងសមុទ្រ

ASEAN Working Group on Nature Conservation (AWGNC)
ក្រុមការងារអាស៊ានស្តីពីអភិរក្សធម្មជាតិ

ASEAN Working Group on Regional Specialized Meteo-rological Centre (AWG/RSMC)
ក្រុមការងារអាស៊ានស្តីពីមជ្ឈមណ្ឌលឧត្តុនិយមវិទ្យាពិសេសប្រចាំតំបន់

ASEAN Working Group on Tax Matters (AWGTM)
ក្រុមការងារអាស៊ានស្តីពីបញ្ហាពន្ធ

(ក្រុមការងាររបស់គណៈកម្មាធិការហិរញ្ញវត្ថុនិងធនាគារក៏ត្រូវបាន
ចាត់ទុកថា ជាក្រុមការងារ អាស៊ាន ស្តីពីបញ្ញពាណិជ្ជកម្មដែរ)

ASEAN–10 + Japan, China, South Korea (ASEAN 10 + 3) = ASEAN-10 + ជប៉ុន + ចិន + កូរ៉េខាងត្បូង (៣)

ASEAN-10 អាស៊ាន-១០
ជាពាក្យដែលគេហៅសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ដែល គេរំពឹងថា
នឹងមានសមាជិកប្រទេសទាំង ១០នៅអាស៊ី អគ្នេយ៍
ហើយដែលជាបំណងរបស់បិតាស្ថាបនិកអាស៊ាន
លើទស្សនៈអំពីការបង្រួបបង្រួមប្រជាជាតិទាំងអស់នៅអាស៊ីអគ្នេយ៍
(The United of Southeast Asia) ។ គេរំពឹង ថា
បំណងរបស់បិតាស្ថាបនិកអាស៊ាន ស្តីអំពីអាស៊ាន-១០
នឹងក្លាយជាការពិតមិនហួសពីឆ្នាំ ២០០០ ឡើយ ។

ASEAN-6 អាស៊ាន-៦
ជាពាក្យដែលគេហៅសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ដែលមាន
សមាសភាពសមាជិកចំនួន ប្រាំមួយគឺ ប្រ៊ុយណេដារូសាឡាំ
(ចូលជាសមាជិក នៅឆ្នាំ ១៩៨៤) ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន
សិង្ហបូរី និងថៃឡង់ដ៍ (១៩៦៧)

ASEAN-Australia Economic Cooperation Programme (AAECP)
កម្មវិធីសហប្រតិបត្តិការ សេដ្ឋកិច្ច អូស្ត្រាលី អាស៊ាន

ASEAN-Canada Business Council (ACBC)
ក្រុមប្រឹក្សាពាណិជ្ជកម្ម កាណាដា អាស៊ាន

ASEAN-Canada Joint Cooperation Committee (ACJCC)
គណៈកម្មាធិការសហប្រតិបត្តិការរួមអាស៊ាន_កាណាដា

ASEAN-Canberra Consultative Meeting (ACCM)
កិច្ចប្រជុំពិគ្រោះយោបល់ កាន់បេរ៉ា អាស៊ាន

ASEAN-EC Economic Ministers' Meeting (AEEM)
កិច្ចប្រជុំរដ្ឋមន្ត្រីស្តីពី សេដ្ឋកិច្ច អាស៊ាន សហគមអឺរ៉ុប
ASEAN-EC Energy Management Training and Resource Centre
មជ្ឈមណ្ឌលបណ្តុះបណ្តាលការគ្រប់គ្រងខាងធនធាន និងថាមពល អាស៊ាន សហគមអឺរ៉ុប
ASEAN-EC Ministerial Meeting on Economic Matters (AEEMM)
កិច្ចប្រជុំក្រសួងស្តីពី បញ្ហាសេដ្ឋកិច្ច អាស៊ាន សហគមអឺរ៉ុប
ASEAN-EU Cooperation Agreement
កិច្ចព្រមព្រៀងសហប្រតិបត្តិការ អាស៊ាន សហគមអឺរ៉ុប
ASEAN-Mekong Basin Development Cooperation Scheme
គំរោងសហប្រតិបត្តិការអភិវឌ្ឍន៍ អាងទន្លេមេគង្គ អាស៊ាន
ASEAN-New Zealand Dialogue Partner (ANDP) ដៃគូចរចាអាស៊ាន ញូសឺឡែន
ASEAN-N-Korea Dialogue Partner (ANKDP) ដៃគូចរចាអាស៊ាន-កូរ៉េខាងជើង
ASEAN-ROK Fund មូលនិធិអាស៊ាន សាធារណរដ្ឋកូរ៉េ
ASEAN-Russia Dialogue Partner (ARDP) ដៃគូចរចាអាស៊ាន-រុស្ស៊ី
ASEAN-S-Korea Dialogue Partner (ASKDP) ដៃគូចរចាអាស៊ាន-កូរ៉េខាងត្បូង
ASEAN-US Business Council (AUSBC)
ក្រុមប្រឹក្សាពាណិជ្ជកម្ម(ធុរកិច្ច)អាស៊ានសហរដ្ឋអាមេរិក
ASEAN-US Initiative (AUI)
ការផ្តួចផ្តើមគំនិតរបស់អាស៊ាន-សហរដ្ឋអាមេរិក
(បានពីភាក្យាក្នុងកិច្ចប្រជុំថ្នាក់ រដ្ឋមន្ត្រីសេដ្ឋកិច្ចនៅ សឹង្ហបូរី នាថ្ងៃទី២៩-៣០ ខែតុលា ឆ្នាំ ១៩៨៧។ ការផ្តួចផ្តើមគំនិតរបស់អាស៊ាន-សហរដ្ឋអាមេរិក មានបំណងផ្តល់នូវច្រកចូលទៅកាន់ទីផ្សារសហរដ្ឋអាមេរិក ដែលអាចព្យាករណ៍ជាអចិន្ត្រៃយ៍ សំរាប់ផលិតផលអាស៊ាន) ។

ASEAN-wide trade diversion
ការធ្វើពាណិជ្ជកម្មដោយបង្វែរទិសដ៏ទូលំទូលាយរបស់អាស៊ាន

Asia and Pacific Area (APA) តំបន់អាស៊ី និង ប៉ាស៊ីហ្វិក

Asia Europe Foundation (ASEF) មូលនិធិអាស៊ីអឺរ៉ុប

Asia Pacific Economic Cooperation (APEC)
កិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ច អាស៊ីប៉ាស៊ីហ្វិក
គឺជាកិច្ចសហប្រតិបត្តិការ ដែលបានបង្កើតឡើងនូវ ឆ្នាំ ១៩៨៩ (កាន់បេរ៉ា, អូស្ត្រាលី) សមាជិកស្ថាបនិកចំនួន ១២គឺ: សហរដ្ឋអាមេរិក ជប៉ុន កាណាដា អូស្ត្រាលី ញូវហ្សេឡង់ដ៏ កូរ៉េខាងត្បូង និងប្រទេសប្រាំមួយនៃសមាគមប្រជាជាតិអាស៊ី អាគ្នេយ៍ (ប្រ៊ូណេ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបូរី និងថៃឡង់ដ៍)។ ប្រទេសចិនប្រជាមានិត តៃវ៉ាន់ និង ហុងកុងបានចូលជាសមាជិកនៅឆ្នាំ ១៩៩១។ ហើយនៅឆ្នាំ ១៩៩៣ ប្រទេស មិកស៊ិកូ និង ប្រទេស ប៉ាពួរញូវហ្គេញ៉ា ត្រូវបានអនុញ្ញាតិ អោយចូលជាសមាជិក។ ប្រទេសឈីលីបានចូលរួមក្នុង អង្គការអន្តរតំបន់នេះនៅឆ្នាំ ១៩៩៤។ បច្ចុប្បន្នប្រទេស វៀតណាម និង ប្រទេស ប៉េរូ ចូលជាសមាជិករួចហើយ ។ កិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិកបាន និង កំពុងអនុវត្តសហប្រតិបត្តិ ការយ៉ាងទូលំទូលាយ តាមមុខព្រួញសំខាន់។ បីគឺ:
១. សេរីភាវូបនីយកម្មពាណិជ្ជកម្ម,
២. សំរួលកិច្ចការ ពាណិជ្ជកម្ម, និង
៣. សហប្រតិបត្តិការបច្ចេកទេស។ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិក មានលេខាធិការដ្ឋាននៅទីក្រុង សិង្ហបូរី ។

Asia-Europe Foundation (AEF) មូលនិធិអាស៊ីអឺរ៉ុប

Asia-Europe Meeting (ASEM)
កិច្ចប្រជុំអាស៊ី-អឺរ៉ុប

គឺជាកិច្ចប្រជុំថ្នាក់ប្រធានរដ្ឋបាល នៃប្រទេសជាសមាជិកសហគមន៍អឺរ៉ុប និងអាស៊ី (ប្រទេសសមាជិក អាស៊ាន-៦ សាធារណរដ្ឋប្រជាមានិតចិន ជប៉ុន និង សាធារណរដ្ឋកូរ៉េ) ។

កិច្ចប្រជុំអាស៊ី-អឺរ៉ុបនេះ ត្រូវបានផ្តួចផ្តើមគំនិតឡើងដោយ នាយករដ្ឋមន្ត្រីសិង្ហបូរី ហ្គូ ចុកតុង នៅចុងឆ្នាំ ១៩៩៤ ក្នុងគោលបំណងបង្កើតជាវេទិកាសន្ទនារវាង សហគមន៍អឺរ៉ុប និងអាស៊ី គឺបន្ថែមភ្ជាប់ចំណងទំនាក់ទំនងរវាងសហគមន៍អឺរ៉ុប និង សហរដ្ឋអាមេរិក ហើយនិងរវាងសហរដ្ឋអាមេរិក និង អាស៊ីតាមរយៈកិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិក (APEC) ។ ដូច្នេះតាមទស្សនៈនេះ គេនឹងបង្កើតបាននូវរចនាសម្ព័ន្ធ សហប្រតិបត្តិការ ត្រីកោណ អន្តរទ្វីបមួយដែលផ្សាភ្ជាប់ អាស៊ី-សហគមន៍អឺរ៉ុប-សហរដ្ឋអាមេរិក។ កិច្ចប្រជុំអាស៊ី-អឺរ៉ុបលើកទីមួយ បានប្រព្រឹត្តទៅពីថ្ងៃ ទី០១-០២ ខែមីនា ឆ្នាំ១៩៩៦ នៅទីក្រុង បាងកក នាប្រទេសថៃឡង់ដ៏។ កិច្ចប្រជុំអាស៊ី-អឺរ៉ុប លើកទីពីរ ធ្វើឡើងនៅ ថ្ងៃទី ០៣-០៤ ខែមេសា ឆ្នាំ១៩៩៨ នៅទីក្រុងឡុងដ៏នាប្រទេសអង់គ្លេស រីឯកិច្ចប្រជុំអាស៊ី-អឺរ៉ុបលើកទីបី នឹងគ្រោងធ្វើនៅឆ្នាំ ២០០០ នៅទីក្រុងសេអ៊ូល នៃសាធារណៈរដ្ឋកូរ៉េ។

Asian American Free Labor Institute (AAFLI)
វិទ្យាស្ថានសេរីភាពការងារ អាស៊ី អាមេរិកកាំង

Asian Development Bank (ADB) ធនាគារអភិវឌ្ឍន៍អាស៊ី

Asian Disaster Prevention Center (ADPC)
មជ្ឈមណ្ឌលការពារគ្រោះមហន្តរាយរបស់ អាស៊ាន

Asia-Pacific Ministerial Seminar on Building Capacity for Fighting Transnational Organized Crime
អាស៊ានសិក្ខាសាលាក្រសួង អាស៊ី ប៉ាស៊ីហ្វិកស្តីពី ការកសាង សមត្ថភាពតតាំង ជាមួយ ក្រុមឧក្រិដ្ឋកម្មឆ្លងដែនដែលមានការរៀបចំ

Association for Agricultural Development (AAD)
សមាគមសំរាប់ការអភិវឌ្ឍន៏កសិកម្ម
Association of Medical for Asia (AMDA)
សមាគមវិជ្ជបណ្ឌិតខាងពេទ្យសំរាប់អាស៊ី
Association of Natural-Rubber Producing Countries (ANRPC)
សមាគមនៃ ប្រទេសដែលផលិតកៅស៊ូធម្មជាតិ
សមាគមនេះបង្កើតឡើងក្នុង ឆ្នាំ ១៩៧០ និងមានប្រទេស ចំនួន ៨ ចូលរួមៈ ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ស្រីលង្កា សឹង្ហបុរី ថៃឡង់ដ៏ វៀតណាម ពួព័រញូវហ្គេញ៉ា និងឥណ្ឌា។ សមាគមនេះ បង្កើតឡើងក្នុងគោលបំណងកែលំអស្ថានភាពទីផ្សារដោយរួមទាំងការការពារផលិតករតូចតាចផងដែរ ។
Association of Southeast Asia (ASA)
សមាគមអាស៊ីអគ្នេយ៏
បង្កើតឡើងនៅឆ្នាំ១៩៦១ ដោយប្រទេសស្ថាបនិកបីគឺៈ ម៉ាឡេស៊ី ហ្វីលីពីន និងថៃឡង់ដ៏ ។ សមាគមបានបដិសន្ធិឡើង ស្របតាមគំនិតផ្តួចផ្តើមរបស់អតីតនាយករដ្ឋមន្ត្រីម៉ាឡេស៊ី អាប់ឌុលរ៉ាម៉ាន់ (Abdul Rahman) ។
ដោយមានទំនាស់ត្រីកោណរវាងឥណ្ឌូណេស៊ី-ហ្វីលីពីន-ម៉ាឡេ ស៊ី ទៅលើបញ្ហារដ្ឋ Sabah និង Sarawak សមាគមអាស៊ីអគ្នេយ៏មិនត្រឹមតែមិនបានទទួលការគាំទ្រ ពីប្រទេសឥណ្ឌូណេស៊ីតែប៉ុណ្ណោះទេ តែថែមទាំងត្រូវរលាយទៅវិញ។
Association of Southeast Asian Institution of Higher Learning (ASAIHL)
សមាគមនៃវិទ្យាស្ថានសិក្សាជាន់ខ្ពស់ អាស៊ីអគ្នេយ៏
Association of Southeast Asian Nations (ASEAN)
សមាគមប្រជាជាតិអាស៊ី-អគ្នេយ៏ បង្កើតឡើងតាមរយៈការចុះហត្ថលេខាលើសេចក្តីប្រកាសទីក្រុងបាងកកកាលពីថ្ងៃទី ០៨ ខែសីហា ឆ្នាំ១៩៦៧ ដោយ

ប្រទេសស្ថាបនិកចំនួនប្រាំគឺៈ ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃឡង់ដ៏។

Association of the Cambodian Local Economic Development Agencies (ACLEDA)

សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចស្រុកភូមិរបស់កម្ពុជា

Australia System of Trade Preferences (ASTP)

ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មរបស់អូស្ត្រាលី

Australia, New Zealand and United States System of International Trade

ប្រព័ន្ធពានិជ្ជកម្មអន្តរជាតិ របស់សហរដ្ឋអាមេរិក ញូសីឡែន និងអូស្ត្រាលី

Australian Agency for International Development (Aus AID)

ទីភ្នាក់ងាររបស់អូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ

Australian Center for Education (ACE) មជ្ឈមណ្ឌលអប់រំរបស់អូស្ត្រាលី

Australian Labor Party (ALP) គណៈបក្សពលករអូស្ត្រាលី

Australia-New Zealand Closer Economic Relation Trade Agreement (CERTA)

កិច្ចព្រមព្រៀងទំនាក់ទំនងសេដ្ឋកិច្ចពាណិជ្ជកម្មយ៉ាងជិតស្និទ្ធ របស់អូស្ត្រាលី និងញូសីឡែន

Automatic Data Exchange (ADE) ការផ្លាស់ប្តូរទិន្នន័យដោយស្វ័យប្រវត្តិ

Automatic Transfer Service (ATS) សេវាផ្លាស់ប្តូរដោយស្វ័យប្រវត្តិ

Automotive Preferences Negotiating Group (APNG)

ក្រុមចរចាមានការអនុគ្រោះដោយស្វ័យប្រវត្តិ

Autoregressive Integrated Moving Average (ARIMA)

ដំណើរធ្វើសមាហរណកម្មទៅក្រោយដោយស្វ័យប្រវត្តិជាមធ្យម

Average Cost (AC) ថ្លៃដើមជាមធ្យម

Average Product (AP) ផលិតផលជាមធ្យម

Average Propensity to Consume (APC) ឧបនិស្ស័យប្រើប្រាស់ជាមធ្យម

Average Revenue (AR) ចំណូលលក់ជាមធ្យម

Average Total Cost (ATC) ថ្លៃដើមសរុបជាមធ្យម

Average Variable Cost (AVC) ថ្លៃដើមឡើងចុះជាមធ្យម

## B

Bachelor of Agricultural Science (BASc) បរិញ្ញាប័ត្រខាងវិទ្យាសាស្ត្រកសិកម្ម

Bachelor of Art (BA) បរិញ្ញាប័ត្រផ្នែកអក្សរសាស្ត្រមនុស្សសាស្ត្រ

Bachelor of Business Administration (BBA) បរិញ្ញាប័ត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្ម

Bachelor of Laws (BL) បរិញ្ញាប័ត្រផ្នែកច្បាប់

Bachelor of Religious Education (BRC) បរិញ្ញាប័ត្រផ្នែកការអប់រំសាសនា

Bachelor of Science (BS) បរិញ្ញាប័ត្រផ្នែកវិទ្យាសាស្ត្រ

Balance of Payment Surplus តុល្យការនៅសល់ក្រោយពីសំណងរួច

Balance of Payments Deficit ឱនភាពជញ្ជីងទូទាត់

Balance of Payments Excess សមតុល្យវិជ្ជមានជញ្ជីងទូទាត់

Balance of Power តុល្យភាពអំណាច

Balance of Trade ជញ្ជីងពាណិជ្ជកម្ម

Balance on Goods and Services សមតុល្យទំនិញ និង សេវាកម្ម

Balance on the Credit Side សមតុល្យផ្នែកឥណទាន

Balance on the Debit Side សមតុល្យផ្នែកឥណពន្ធ

Balance Sheet តារាងតុល្យការ

Balance Sheet of National Economy តារាងតុល្យការសេដ្ឋកិច្ចជាតិ

Bangkok Declaration

សេចក្តីថ្លែងការណ៍ទីក្រុងបាងកក គឺជាសេចក្តីថ្លែងការណ៍បង្កើតអាស៊ាន នៅថ្ងៃទី ៨ ខែសីហា ឆ្នាំ ១៩៦៧ នាទីក្រុងបាងកកដោយប្រទេស៥ គឺឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និង ថៃឡង់ដ៏

Bangkok International Banking Facility (BIBF) សម្បទាធនាគារអន្តរជាតិបាងកក

Bank Acceptance ប័ណ្ណទទួលស្គាល់របស់ធនាគារ

Bank Account គណនីធនាគារ

Bank Advance កម្ចីធនាគារ

Bank Balance សមតុល្យធនាគារ

Bank Bill វិក័យប័ត្រធនាគារ

Bank Book សៀវភៅផ្ញើប្រាក់នៅធនាគារ

Bank Borrowing ប្រាក់ខ្ចីពីធនាគារ

Bank Charges គិតថ្លៃសោហ៊ុយធនាគារ

Bank Cleaning ការទូទាត់តាមធនាគារ

Bank Draft រូបិយាណត្តិ " សែកធានាគារ"

Bank Fees សោហ៊ុយធនាគារ

Bank Guaranty Credit Scheme គំរោងឥណទានធនាគារ

Bank Note (B/N) លិខិតស្នាមរបស់ធនាគារ

Bank of Credit and Commerce International (BCCI)
ធនាគារឥណទាន និង ពាណិជ្ជកម្មអន្តរជាតិ

Bank of International Settlement (BIS) ធនាគារសំរុះសំរួលអន្តរជាតិ

Bank of Thailand ធនាគារថៃ

Bank Rate អត្រាការប្រាក់ធនាគារ

Bank Reference សេចក្តីបញ្ជាក់ពីធនាគារ

Bank Transfer ការផ្ទេរប្រាក់នៅធនាគារ

Bankruptcy ការក្ស័យធន

Bankruptcy Law ច្បាប់ស្តីអំពីការក្ស័យធន

Bargain and Sale ការតថ្លៃនិងទិញលក់

Bargain Offer អោយថ្លៃ
Bargain Price ថ្លៃថោក
Barrels Per Day (B/D) ធុងក្នុងមួយថ្ងៃ
Barrier on Certain Goods របាំងនៃការនាំចូលទំនិញមួយចំនួន
Barter Agreement Goods កិច្ចព្រមព្រៀងផ្លោះប្តូរទំនិញ និង ទំនិញ
Base Rate អត្រាជាមូលដ្ឋាន
Basic Agreement on ASEAN Industrial Complementation (BAAIC)
កិច្ចព្រមព្រៀងជាមូលដ្ឋាន ស្តីពីការបំពេញបន្ថែម ផ្នែកឧស្សាហកម្មអាស៊ាន
Basic Agreement on ASEAN Joint Ventures (BAAIJV)
កិច្ចព្រមព្រៀង ជាមូលដ្ឋានស្តីពី សហគ្រាសឧស្សាហកម្មចំរុះអាស៊ាន
Basic Assumption សេចក្តីសន្មតជាមូលដ្ឋាន
Basic Commodity របស់ប្រើប្រាស់ជាចាំបាច់
Basic Discount ការបញ្ចុះតម្លៃជាចាំបាច់
Basic Human Needs (BHN) តំរូវការជាមូលដ្ឋានរបស់មនុស្ស
Beginner's All Purpose Symbolic Instruction Code (BASIC)
ក្រុមណែនាំនូវនិមិត្តសញ្ញា គោលបំណងទាំងឡាយសំរាប់ អ្នកចាប់ផ្តើម "ជាភាសាមួយរបស់កុំព្យូទ័រ"
Benchmark Survey ការអង្កេតវាយតំលៃ លើការអនុវត្តន៍លក្ខខណ្ឌ
Best Linear Unbiased Estimators (BLUE)
អ្នកប៉ាន់ស្មានក្នុងលក្ខណៈត្រឹមត្រូវបំផុតមិនមានការលៀង
Biannual Monitoring ការតាមដាន និងត្រួតពិនិត្យ២ដងក្នុងមួយឆ្នាំ
Bilateral Assistance ជំនួយទ្វេភាគី
Bilateral Cooperation សហប្រតិបត្តិការទ្វេភាគី
Bilateral Donor ម្ចាស់អំណោយទ្វេភាគី

Bilateral Investment Treaty (BIT) សន្ធិសញ្ញាស្តីពីវិនិយោគទ្វេភាគី

Bill of Collection វិក័យប័ត្រប្រមូលប្រាក់

Bill of Exchange លិខិតផ្លាស់ប្តូរ

Bill of Lading បញ្ជីឈ្មោះទំនិញដឹកជញ្ជូន បង្កាន់ដៃផ្ទុកទំនិញ

Bill of Payable វិក័យប័ត្រត្រូវចំណាយ

Biological Weapon Convention (BWC) សម័យប្រជុំសព្វាវុធនៃជីវសាស្ត្រ

Blackly កម្មករដែលនៅតែធ្វើការនៅពេលមានកូដកម្មនានា

Blanket Agreement កិច្ចព្រមព្រៀងដែលបញ្ចូលបញ្ហាគ្រប់មុខ

Blockade ការហ៊ុំព័ទ្ធ

Board Meeting កិច្ចប្រជុំរបស់ក្រុមនាយក

Board of Directors ក្រុមប្រឹក្សានាយក

Board of Enquiry ក្រុមប្រឹក្សាអង្កេត

Board of Investment (BOI) ក្រុមប្រឹក្សាវិនិយោគ

Board of Management ក្រុមប្រឹក្សាគ្រប់គ្រង

Board of Planners (BOP) ក្រុមប្រឹក្សាអ្នកធ្វើគំរោង

Board of Trustees ក្រុមប្រឹក្សាភិបាល

Bond Holder អ្នកកាន់ប័ណ្ណរដ្ឋាភិបាល

Bonded Warehouse ឃ្លាំងស្តុកទំនិញដែលពុំទាន់បង់ពន្ធ

Bonn ASEAN Committee (BAC) គណៈកម្មាធិការ អាស៊ាន នៅទីក្រុងបោន

Boom Industry ឧស្សាហកម្មដែលអភិវឌ្ឍន៍

Boom Share ហ៊ុនដែលរីកសាយភាយ

Boom Year ឆ្នាំមានសេដ្ឋកិច្ចរីកចំរើន

Borrowed Reserves ប្រាក់បំរុងសំរាប់អោយខ្ចី

Borrower អ្នកខ្ចី

Boundary ព្រំដែន

Brackishwater Aquaculture Development Centre (BADC)
មជ្ឈមណ្ឌលរៀបចំចិញ្ចឹមរាល់ជីវិតសត្វ
រស់នៅក្នុងទឹកសាបលាយទឹកសមុទ្រ

Brand Image រូបសញ្ញាពាណិជ្ជកម្ម

Brand Name យីហោផលិតផល

Brand New ថ្មីស្រឡាង

Brand Owner ម្ចាស់កម្មសិទ្ធិយីហោ

Branded Goods ទំនិញមានផ្លាកសញ្ញ

Brand-Related Original Equipment Manufacturer (BROEM)
សហគ្រាសផលិតបរិក្ខារដើម ដែលពាក់ព័ន្ធដល់យីហោ

Brand-to-Brand Complementation (BBC)
ការបំពេញយីហោអោយគ្នាទៅវិញទៅមក
(នៅក្រោមកិច្ចព្រមព្រៀង BAAIC
ដែលបានឯកភាពដោយកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី សេដ្ឋកិច្ច
នៅទីក្រុងចាំតាយ៉ា នាថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៨៨)

Brand-to-Brand Parts/Components Manufacturer (BBPM)
ផ្នែកផ្លាកសញ្ញាពីមួយទៅមួយ រឺ សមាសភាគ ក្រុមអ្នកផលិត

Breach of Contract ការល្មើសកិច្ចសន្យា

Breach of Warranty ការល្មើសនឹងការធានា

British Broadcasting Corporation (BBC) ក្រុមហ៊ុនផ្សព្វផ្សាយពត៌មានរបស់អង់គ្លេស

Brokers Telegraph System (BST) ក្រុមអ្នកប្រពន្ធ័បញ្ជូនសារ

Brunei-Indonesia-Malaysia-Philippines East ASEAN Growth Area (BIMP-EAGA)

តំបន់រីកលូតលាស់អាស៊ានខាងកើតមាន ប្រ៊ុយណេ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និង ហ្វីលីពីន

Brussels Definition of Value (BDV) និយមន័យនៃ Brussels

Buddhist Association for the National Reconciliation of Cambodia (BANRC) សមាគមព្រះពុទ្ធសាសនាសំរបសំរួលជាតិកម្ពុជា

Budget Account គណនីថវិកា

Budgetary Control ការត្រួតពិនិត្យចំណាយថវិកា

Budgetary Policy គោលនយោបាយថវិកា

Buffer Stock Facility (BSF) ឧបករណ៍សំរួលសំរាប់ទប់សន្និធិ

Build Operate and Transfer (BOT) សាងសង់ ដំណើរការ និង ផ្ទេរគឺជាការវិនិយោគឯកជនដោយអនុលោមទៅតាម ល័ក្ខខ័ណ្ឌបីគឺ : សាងសង់អ្វីមួយបន្ទាបមកដំណើរការដោយបានប្រាក់មកវិញតាមរយៈការជួល ឬ ផ្តល់សេវាកម្ម និង ចុងក្រោយប្រគល់ជូនរដ្ឋ (មានកិច្ចសន្យាច្បាស់លាស់)

Building Code of Conduct បង្កើតការគោរពច្បាប់

Bumiputra ជនជាតិដើមម៉ាឡេ (នយោបាយលើកស្ទួយជនជាតិម៉ាឡេ)

Bureau de Change ការិយាល័យប្តូរប្រូបីយវត្ថុបរទេស

Bureaucracy ការិយាធិបតេយ្យ

Business Archives Council (BAC) ក្រុមប្រឹក្សាឯកសារពាណិជ្ជកម្ម

Business Center មជ្ឈមណ្ឌលពាណិជ្ជកម្ម

Business Class ថ្នាក់ជំនួញ (កន្លែងលើយន្តហោះ មានតំលៃមធ្យម)

Business Efficiency Exhibition ពិពណ៌ស្តីពីប្រសិទ្ធិភាពពាណិជ្ជកម្ម

Business Equipment គ្រឿងបរិក្ខាប្រើនៅក្នុងការិយាល័យ

Business Format Franchising
ការផ្តល់សិទ្ធិអោយគេរកស៊ីដោយគោរពច្បាប់ក្រុមហ៊ុនជាម្ចាស់

Buying Power — កំលាំងសរុបរបស់ទឹកប្រាក់ដែលមានចំនួនច្រើន

By Product — អនុផល

## C

Cable News Network (CNN)
ប្រព័ន្ធពត៌មានខ្សែកាប (បុស្តិ៍ផ្សាយពត៌មាន២៤ ម៉ោង ស៊ី អិន អិន)

Cambodia and Family Services International (CFSI)
អង្គការអន្តរជាតិកម្ពុជាសំរាប់បំរើគ្រួសារ

Cambodia British Centre (CFBT) មជ្ឍមណ្ឌល កម្ពុជា អង់គ្លេស

Cambodia Development Resource Institute (CDRI)
វិទ្យាស្ថាន បណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) គឺជាស្ថាប័នឯករាជ្យ និងមិនមែនរដ្ឋាភិបាល មានទិសដៅស្រាវជ្រាវ និងបណ្តុះបណ្តាល សមត្ថភាពធនធានមនុស្ស។ វបសអ បង្កើតឡើងនៅឆ្នាំ ១៩៩០ មានទីតាំងនៅរាជធានី ភ្នំពេញ ។

Cambodia Family Development Services (CFDF) អង្គការអភិវឌ្ឍន៍គ្រួសារ កម្ពុជា

Cambodia Import-Export Company (KAMPEXIM) ក្រុមហ៊ុនអាហារណនីហារណ

Cambodia Laos Myanmar Vietnam (CLMV) កម្ពុជា ឡាវ ភូមា វៀតណាម

Cambodia, Laos and Myanmar (CLM) កម្ពុជា ឡាវ និង ភូមា

Cambodia, Laos, Vietnam (CLV) កម្ពុជា-ឡាវ-វៀតណាម

Cambodian American National Development Organization (CANDO)
អង្គការអភិវឌ្ឍន៍ជាតិកម្ពុជា អាមេរិចកាំង

Cambodian Centre for Conflict Resolution (CCCR)
មជ្ឈមណ្ឌលកម្ពុជា សំរាប់ផ្សះផ្សារបង្ការទំនាស់

Cambodian Chamber of Commerce
សភាពាណិជ្ជកម្មកម្ពុជា សភាពាណិជ្ជកម្មកម្ពុជាមិនទាន់មាននៅឡើយទេ ប៉ុន្តែកម្ពុជា មានសភាពាណិជ្ជកម្មប្រចាំរាជធានីភ្នំពេញ ដែលចែកចេញជាបួនផ្នែកគឺ :

១- ផ្នែកឧស្សាហកម្ម និងសិប្បកម្ម

២- ផ្នែកពាណិជ្ជកម្ម

៣- ផ្នែកសេវាកម្ម និងអាជីវកម្ម

៤- ផ្នែកកសិកម្ម

Cambodian Customs Tariff (CCT) តារាងពន្ធគយកម្ពុជា

Cambodian Foundation for Education and Development (CAMFED)
មូលនិធិកម្ពុជា សំរាប់ការអប់រំ និង អភិវឌ្ឍន៍

Cambodian Human Rights Association (CHRA) សមាគសិទ្ធិមនុស្សកម្ពុជា

Cambodian Human Rights Coordination (CHRCC)
ការសំរបសំរួលសិទ្ធិមនុស្សកម្ពុជា

Cambodian Human Rights Trainer Organization (CHRTO)
អង្គការអ្នកបណ្តុះបណ្តាលសិទ្ធិមនុស្សកម្ពុជា

Cambodian Humanitarian Foundation (CHF) មូលនិធិសប្បុរសជនកម្ពុជា

Cambodian Institute for Cooperation and Peace (CICP)
វិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និង សន្តិភាព (វ.ខ.ស.ស.) បានបង្កើតក្នុងខែ មិថុនា ឆ្នាំ១៩៩៤ និងមានទីតាំងនៅ រាជធានីភ្នំពេញ។ វ.ខ.ស.ស. គឺជាវិទ្យាស្ថានឯករាជ្យ និង មិនមែនរដ្ឋាភិបាល ហើយមានទិសដៅជំរុញសន្តិភាព និង សហប្រតិបត្តិការ តាមរយៈសន្និបាត សិក្ខាសាលា ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ។ វ.ខ.ស.ស. ជាអ្នក ផ្តួចផ្តើមអោយមានការប្រជុំបើកចំហ ការពិភាក្សាជាសាធរណៈ និង ការវិភាគស្តីពីបញ្ហាសំខាន់ៗនៅកម្ពុជា ក្នុងតំបន់ និង នៅ ក្នុងពិភពលោកទាំងមូល ។

Cambodian Institute of Human Rights (CIHR) វិទ្យាស្ថានខ្មែរ សំរាប់សិទ្ធិមនុស្ស

Cambodian International Development Agency (CIDA)
ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ កម្ពុជា

Cambodian Investment Board (CIB)
ក្រុមប្រឹក្សាវិនិយោគកម្ពុជា (គវិក) គវិក ក្រុមប្រឹក្សាមួយនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាច្រកចេញចូលតែមួយ និង ជាសេនាធិការរាជរដ្ឋាភិបាលក្នុង ការពិនិត្យអោយយោបល់ និងអនុញ្ញាតលើការវិនិយោគនានា ។

Cambodian League for the Promotion and Defense of Human Rights
សម្ព័ន្ធសំរាប់ជំរុញ និង ការពារ សិទ្ធិមនុស្សកម្ពុជា (LICADHO) (Lique Cambodienne pour la promotion et Defense des Droits de L' Homme)
សម្ព័ន្ធខ្មែរជំរឿនការពារសិទ្ធិមនុស្ស

Cambodian Mine Action Center (CMAC)
មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

Cambodian Mine Awareness Committee (CMAC)
គណៈកម្មាធិការ សំរាប់ដាស់តឿនខាងមីនម្ពុជា

Cambodian Programme Director (CPD) ចាងហ្វាងកម្មវិធីកម្ពុជា

Cambodian Red Cross (CRC) កាកបាទក្រហមកម្ពុជា

Cambodian Rehabilitation and Development Board (CRDB)
ក្រុមប្រឹក្សានីតិសម្បទា និងអភិវឌ្ឍន៏កម្ពុជា (គជនា) គជនាជាក្រុមប្រឹក្សាមួយនៃក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ជាអ្នកសំរបសំរួលក្នុងការលើកទស្សនទាន ជាយុទ្ធសាស្ត្រ និង គោលនយោបាយ នៃកិច្ចការវិនិយោគសាធារណៈ ព្រមទាំងជា អ្នកសំរបសំរួល ក្នុងការកំណត់លំដាប់អទិភាព នៃកម្មវិធី និង គំរោងសាធារណៈសំរាប់រយៈពេលមធ្យម។

Cambodian Women Development Agency (CWDA) ទីភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីកម្ពុជា

Canada Free Trade Agreement (CFTA) កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកាណាដា

Canadian International Development Agency (CIDA)
ទីភ្នាក់ងារអភិវឌ្ឍន៍ អន្តរជាតិកាណាដា

Canvasser អ្នកស្ទង់មតិ

Capacity Building ការកសាងសមត្ថភាព

Capital Asset ទ្រព្យមូលធន

Capital Assistance ជំនួយមូលធន, ឧបត្ថម្ភធន

Capital Circulation ការបង្វិលធន

Capital Expenditure ចំណាយមូលធន

Capital Gain Tax ពន្ធលើផលចំណេញជាមូលធន

Capital Goods
ទំនិញមូលធន ទំនិញដែលប្រើប្រាស់សំរាប់ផលិតទំនិញនានាដទៃទៀត (ទំនិញមូលធន នេះមានម៉ាស៊ីន គ្រឿងចក្រ អាគារឧស្សាហកម្ម និង វត្ថុធាតុដើម ។ល។)

Capital Investment ការវិនិយោគមូលធន

Capital Market ផ្សារទុន ផ្សារមូលធន

Capital Movements ការផ្ទេរធន

Capital Outlay ធនចំណាយ

Capital Reserves ធនបំរុង

Capital Support Facility (CSF) សម្បទានសំរាប់ទ្រទ្រង់ធនធាន

Capital Transfers ការផ្ទេរមូលធន

Capital-Intensive Products បណ្ណាផលិតផល ដែលប្រើធនធានច្រើន

Captive Market ទីផ្សារផ្តាច់មុខ

Cargo Insurance ការធានារ៉ាប់រងទំនិញ

Caribbean Community (CARICOM) សហគមន៍ Caribbean រួមមាន ១៣រដ្ឋ

Carriage and Insurance Paid (CPI)
ការដឹកជញ្ជូននិង ធានារ៉ាប់រងដែលបានបង់តំលៃរួច

Carriage Paid (CP) ការដឹកជញ្ជូនដែលបានបង់ថ្លៃរួច

Carriage ការដឹកទំនិញតាមផ្លូវគោក

Cash Against Document (CAD) ប្រគល់ប្រាក់ពេលបានទទួលឯកសារ

Cash Flow Analysis ការវិភាគចរាចរសាច់ប្រាក់

Cash Margin Requirement ការតំរូវតំកល់សាច់ប្រាក់ធនាគារ

Cash on Delivery (COD/c-o-d) បង់ប្រាក់ពេលទទួលទំនិញ

Cash With Order (CWO) បង់ប្រាក់ពេលបញ្ជាទំនិញ

Casino Economy សេដ្ឋកិច្ចកាស៊ីណូ (ការរកស៊ីដាក់ទុនឆាប់ និងដកទុនចេញ)

Ceiling Price ថ្លៃខ្ពស់បំផុត

Center for Irrigation System Management for ASEAN (CISMA)
មជ្ឈមណ្ឌលសំរាប់ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ សំរាប់ អាស៊ាន

Central African Customs and Economic Union (CACEU)
សហភាពគយ និង សហសេដ្ឋកិច្ចទ្វីបអាព្រិចកណ្តាល

Central American Common Market (CACM) ទីផ្សាររួមទ្វីបអាមេរិកកណ្តាល

Central Bank Deputies Meeting កិច្ចប្រជុំតំណាងធនាគារកណ្តាល

Central Intelligence Agency (CIA) ទីភ្នាក់ងារស៊ើបអង្កេតកណ្តាល សេ អ៊ី អា

Central Monetary Agency ទីភ្នាក់ងាររូបិយវត្ថុមជ្ឈឹម

Centralized Economy សេដ្ឋកិច្ចមជ្ឈការ (រដ្ឋជាអ្នកដាក់ផែនការអោយអនុវត្ត)

Centrally-Planned Economy
សេដ្ឋកិច្ចផែនការប្រមូលផ្តុំ (រដ្ឋជាអ្នកដាក់ផែនការ អោយអនុវត្ត)

Centre for Strategic and International Studies (CSIS)
មជ្ឈមណ្ឌលសិក្សា យុទ្ធសាស្ត្រ និង អន្តរជាតិ

Centre for Technology Exchange (CTE) មជ្ឈមណ្ឌលសំរាប់ផ្លាស់ប្តូរបច្ចេកវិទ្យា

Centre for Vocational and Extention Services Training (CEVEST)
មជ្ឈមណ្ឌលហ្វឹកហ្វឺនវិជ្ជាជីវៈ និងសេវាកម្មវិបុលកម្ម

Centre National Hygiène et Epidémiologie (CNHE)
មជ្ឈមណ្ឌលអនាម័យ ការពាររោគរាតត្បាត

Centre of Instructors and Advanced Skills Training(CIAST)
មជ្ឈមណ្ឌលហ្វឹកហ្វឺនគ្រូ និងជំនាញខ្ពង់ខ្ពស់

Certificate of Deposit (CD) លិខិតបញ្ញើ

Certificate of Elogobility (COE) វិញ្ញាប័ត្រនៃភាពដែលអាចទទួលយកបាន

Certificate of Origin (C/O) វិញ្ញាប័ត្រប្រភពទំនិញ

Challenges and Opportunities បញ្ហាប្រឈម និងកាលានុវត្តភាព

Chamber of Commerce សភាពាណិជ្ជកម្ម

Chamber of Commerce and Industry (CCI) សភាពាណិជ្ជកម្ម និងឧស្សាហកម្ម

Charges Levied on Imports តំឡើងបន្ទុកលើការនាំចូល

Chemical Weapons Convention (CWC) សន្ធិបាទស្តីពីអាវុធប្រើជាតិគីមី

Chief Executive Officer (CEO) ប្រធានគ្រប់គ្រងសមាជិក

Chinese Society for EC Studies (CSECS)
សមាគមចិនសំរាប់ការសិក្សាសហគមន៍អឺរុប

Chinese Society for EU Studies (CSEUS)
សមាគមចិនសំរាប់ការសិក្សាសហព័ន្ធអឺរុប

CIF (Cost-Insurance-Freight)
ថ្លៃទំនិញ បូកនឹងថ្លៃធានារ៉ាប់រង ហើយនឹងថ្លៃដឹកជញ្ជូន

Civil Aviation អាកាសចរណ៍ស៊ីវិល

Civil Aviation Authority (CAA) អាជ្ញាធរអាកាសចរណ៍ស៊ីវិល

Clean Technology and Environmental Management (CTEM)
បច្ចេកទេសសំអាតនិងការគ្រប់គ្រងបរិស្ថាន

Closed Market ទីផ្សារផ្គត់ផ្គង់ផ្តាច់មុខ

Closer Economic Relations (CER)
កិច្ចព្រមព្រៀងទំនាក់ទំនង សេដ្ឋកិច្ចពាណិជ្ជកម្មជិតស្និទ អូស្ត្រាលី-នូវែលហ្សេឡង់ គឺជាកិច្ចប្រមព្រៀងដែលបានចូលជាធរមាននៅឆ្នាំ ១៩៨៣ ហើយដែលមានគោលបំណងជំរុញសេរីភាវូបនីពាណិជ្ជកម្ម
តាមរយៈការលប់បំបាត់របាំងពន្ធគយ និង មិនមែនពន្ធគយ និង សាមញ្ញកម្ម (simplify) បទដ្ឋានរដ្ឋបាលផ្សេងៗ ។

Coal Sub-Sector Network (CSN) អនុផ្នែកបណ្តាញធ្យូងថ្ម

Coalition Government of Democratic Kampuchea (CGDK)
រដ្ឋាភិបាលចំរុះ កម្ពុជាប្រជាធិបតេយ្យ

Code of Conduct (COC) ក្រមប្រតិបត្តិរួម

Coercion ការបញ្ចុះបញ្ចូល

Free from external interference, subversion and coercion

Cold War
សង្គ្រាមត្រជាក់ (ជាសង្គ្រាមមនោគមវិជ្ជា រវាងក្រុមប្រទេសប្រកាន់របបកុំមុយនីស្តនិយម) ។

Collective Ownership កម្មសិទ្ធិរួម

Collective សន្តិសុខរួម

Colonialism អាណានិគមនិយម

Commercial Attaché អនុពន្ធពាណិជ្ជកម្ម

Commercial Bank ធនាគារពាណិជ្ជកម្ម

Commercial Counselor ទីប្រឹក្សាពាណិជ្ជកម្ម

Commercial Enterprise សហគ្រាសជំនួញ

Commercialization ពាណិជ្ជនីយកម្ម ការធ្វើអោយទៅជារបរជំនួញ

Commission Contract កិច្ចសន្យាកំរៃជើងសារ

Commission of the European Communities (CEC) គណៈកម្មការសហគមន៍អឺរ៉ុប

Committee for ASEAN Youth Co-operation (CAYC)
គណៈកម្មាធិការ សំរាប់សហប្រតិបត្តិការយុវជនអាស៊ាន
(អង្គការមិនមែន រដ្ឋាភិបាលអាស៊ាន
បញ្ចូលជាផ្លូវការដោយគណៈកម្មាធិកា អចិន្ត្រៃយ៍លើកទី ១៧
របស់អាស៊ាន នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ១៩៨៣)

Committee for Coordination of Joint Prospecting for Minerals in Asian Offshore Areas (CCOP)
គណៈកម្មាធិការសំរបសំរួល ការរុករករ៉ែរួម ក្នុងតំបន់សមុទ្រអាស៊ាន

Committee of Inspection គណៈកម្មាធិការត្រួតពិនិត្យ

Committee of Permanent Representative (COPR)
គណៈកម្មាធិការអ្នកតំណាងអចិន្ត្រៃយ៍

Committee of the Development Cambodia (CDC)
គណៈកម្មាធិការអភិវឌ្ឍន៍កម្ពុជា

Committee on Budget (COB) គណៈកម្មាធិការថវិកា

Committee on Budget and Audit (COBA) គណៈកម្មាធិការថវិកា និងជម្រះបញ្ជី

Committee on Culture and Information (COCI)
គណៈកម្មាធិការវប្បធម៌ និង ពត៌មាន

Committee on Energy Corporation (COEC) គណៈកម្មាធិការសាជីវកម្មថាមពល

Committee on Finance and Banking (COFAB)
គណៈកម្មាធិការ ហិរញ្ញវត្ថុ និង ធនាគារ

Committee on Food, Agriculture and Forestry (COFAF)
គណៈកម្មាធិការ ម្ហូបអាហារ កសិកម្ម និងព្រៃឈើ

Committee on Industry, Minerals and Energy (COIME)
គណៈកម្មាធិការ ឧស្សាហកម្ម រ៉ែ និងថាមពល
Committee on Science and Technology (COST)

Gross Production ផលិតផលសរុប

Gross Profit ប្រាក់ចំណេញសរុប

Gross Salary បៀវត្សពុំទាន់ហូតពន្ធ

Group of Eight (G8)

ក្រុមបរទេសឧស្សាហកម្មជឿនលឿនទាំង៨ របស់ពិភពលោក មានដូចជា: ជប៉ុន រុស្ស៊ី អាមេរិក បារាំង អង់គ្លេស អាឡឺម៉ង់ អ៊ីតាលី និង កាណាដា

Group of Seven (G7)

ប្រទេសឧស្សាហកម្មទាំង ៧ (USA, Canada, Japan, France, Italy, Britain, Germany)

Group of Ten (G10) ប្រទេសឧស្សាហកម្មទាំង ១០

Growth Rate អត្រាកំណើន

Growth Triangle (GT)

ត្រីកោណកំណើន ឬត្រីកោណអភិវឌ្ឍន៍ គឺជាដំណើរកើនឡើងដោយស្មើទៅមុខ ដែលក្នុងនោះ សក្តានុពលបង្កើនផលិតភាពត្រូវបានកើនឡើង ជាលំដាប់ តាមពេលវេលានិងទីកន្លែង តាមរយ:ការធ្វើ សំយោគ (combine) នៃបណ្តាឧត្តមភាពប្រៀបធៀបដែលមាន (overall comparative advantages ។

អាស៊ានបានបង្កើតតំបន់អភិវឌ្ឍន៍ត្រីកោណឥណ្ឌូណេស៊ី-ម៉ាឡេស៊ី-ថៃឡង់ដ៍ (Indonesia-Malaysia-Thailand Growth Triangle IMT-GT), សឹង្ហបុរី-ហ្សូហូ-រីអាវ (Singapore-Johor-Riau Growth Triangle-Sijori) ។ល។

ក្នុងគោលបំណងជំរុញការអភិវឌ្ឍន៍នៅតំបន់នោះ

ដោយបង្កល័ក្ខខ័ណ្ឌអោយប្រទេសចូលរួមនីមួយៗ ប្រើប្រាស់ អោយបានជាអតិបរមានូវឧត្តមភាព ប្រៀបធៀបដែលខ្លួនមាន ។

Guff Cooperation Council (GCC) ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ

Gun-Boat Diplomacy កិច្ចការទូតប្រើកំលាំងគំរាម

## H

Haggle (over the terms of a bargain) ជជែកអំពីល័ក្ខខ័ណ្ឌកុងត្រា

Half Price Sale ការលក់ចុះថ្លៃពាក់កណ្តាល

Hanoi Plan of Action (HPA) គំរោងផែនការនៃសកម្មភាពនៅទីក្រុងហាណូយ

Harbor ផែ

Hard Bargain ការចរចាដ៏តឹងតែង

Hard Cash សាច់ប្រាក់ខ្លាំង, សាច់ប្រាក់មានប្រសិទ្ធិភាព

Hard Condition ល័ក្ខខ័ណ្ឌតឹងរឹង

Hard Loan ឥណទានដែលមានការប្រាក់ខ្ពស់

Hard Money លុយមានទំនុកចិត្ត

Hard Sell ការលក់ដោយលំបាក

Harmonized System (HS)
ប្រព័ន្ធស៊ីសង្វាក់គ្នា (ស្របគ្នា) (ក្នុងការរៀបចំតារាងពន្ធគយ)

Hazard Analysis Critical Control Point (HACCP)
ចំណុចត្រួតពិនិត្យ យ៉ាងជិតដល់លើការវិភាគអំពីគ្រោះថ្នាក់

Head of ASEAN Power Unity Authority (HAPUA)
ក្រុមអជ្ញាធរដឹកនាំនូវការបង្រួបបង្រួមអំណាចអាស៊ាន

Head of Government (HG) ប្រមុខរដ្ឋាភិបាល

Head of Mission (HOM) ប្រមុខគណៈប្រតិភូ

Head Office, Home Office (HO) ការិយាល័យកណ្តាល ឬការិយាល័យនៅផ្ទះ

Headquarters (HQ) ទីបញ្ជាការ

Heads of National Drug law Enforcement Agencies (HONDLEA)
ប្រធានទីភ្នាក់ងារជាតិសំរាប់ពង្រឹងការអនុវត្តន៍ ច្បាប់ប្រឆាំងគ្រឿងញៀន

Healthy Balance Sheet តារាងតុល្យភាពដែលល្អប្រសើរ

Heavy Cost ចំណាយច្រើន ថ្លៃខ្ពស់

Heavy Industry ឧស្សាហកម្មធុនធ្ងន់

Heavy Machinery គ្រឿងម៉ាស៊ីនធំៗ

Hegemomism អនុត្តរភាព

Hegemony មេដឹកនាំ (មេដឹកនាំរដ្ឋមួយ ក្នុងក្រុមនៃរដ្ឋ)

High Council ក្រុមប្រឹក្សាជាន់ខ្ពស់ (ដោះស្រាយចំពោះគ្រប់ករណី)

High Education ឧត្តមសិក្សា

High Level Consultation (HLC) ការពិគ្រោះយោបល់កិរិតជាន់ខ្ពស់

High Level Steering Committee (HLSC)
គណៈកម្មាធិការដឹកនាំជាន់ខ្ពស់ (មន្ត្រីជាន់ខ្ពស់ពីក្រសួងការបរទេស និងសេដ្ឋកិច្ច ដើម្បី រៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៣ ពីថ្ងៃទី១៤-១៦ ខែធ្នូ ឆ្នាំ១៩៨៧ នៅទីក្រុងម៉ានីល)

High Level Working Party (HLWP) ក្រុមការងារជាន់ខ្ពស់

High-Employment GDP (Y*) GDP ការមានការងារធ្វើច្រើន (potential GDP)

High-Employment National Income (Y*) ចំណូលជាតិអនិកម្មភាពខ្ពស់

High-Grade Trade Delegation គណៈប្រតិភូពាណិជ្ជកម្មជាន់ខ្ពស់

High-Level Decision សេចក្ដីសំរេចចិត្តដោយមន្ត្រីជាន់ខ្ពស់

Highly Sensitive List បញ្ជីវេយិតភាពខ្លាំង

High-Purchase ការទិញបណ្ដាក់

Hire-Purchase Agreement កិច្ចព្រមព្រៀងទិញ-លក់បណ្ដាក់

Hire-Purchase Company ក្រុមហ៊ុនទិញ-លក់បណ្ដាក់

His Excellency (HE) ឯកឧត្តម

His Royal Majesty (HRM) ព្រះករុណាជាម្ចាស់ជីវិតតំកល់លើត្បូង

His/ Her Highness (HH) ព្រះករុណា

His/Her Majesty (HM) ព្រះករុណាថ្លៃវិសេស. ព្រះអង្គម្ចាស់ជីវិតតំកល់លើត្បូង

His/Her Royal Highness (HRH) ព្រះអង្គម្ចាស់. អ្នកអង្គម្ចាស់

Holding Company ក្រុមហ៊ុនកាន់កាប់ទ្រព្យសម្បត្តិភាគហ៊ុនផ្សេងៗ

Home Based Staff បុគ្គលិកមូលដ្ឋានគ្រឹះ

Home Consumption Value (HCV) តម្លៃប្រើប្រាស់នៅក្នុងផ្ទះ ឬក្នុងប្រទេស

Home Country ស្រុកកំណើត

Home Trade ពាណិជ្ជកម្មក្នុងស្រុក

Home-Produced Products ផលិតផលផលិតក្នុងស្រុក

Honorary Secretary (Hon. Sec) លេខាកិត្តិយស

Host Country ប្រទេសម្ចាស់ផ្ទះ

Hot Money លុយ ឬប្រាក់ក្តៅ
(លុយដែលបានមកពីការប្រព្រឹត្តនូវអំពើមិនគម្បី)

Human Capital Investment ការវិនិយោគទុនទៅលើធនធានមនុស្ស

Human Development Fund មូលនិធិអភិវឌ្ឍន៍ធនធានមនុស្ស

Human Immune Deficiency Virus (HIV)
វីរុសហ៊ីវ (ការខ្វះខាតសារធាតុការពារជំងឺនៅក្នុងខ្លួន)

Human Resource Development Project (HRDP)
គំរោងអភិវឌ្ឍន៍ធនធានមនុស្ស

Human Resources Development (HRD) ការអភិវឌ្ឍន៍ធនធានមនុស្ស

Human Resources Management (HRM) ការគ្រប់គ្រងធនធានមនុស្ស

Human Rights សិទ្ធិមនុស្ស

Hunting and Forest Department នាយកដ្ឋានរុក្ខាប្រមាញ់

Hydroelectric Power វារីអគ្គិសនី

Hydrology and Weather Department នាយកដ្ឋានធារាសាស្ត្រ និង ឧត្តុនិយម

Hyperinflation អតិផរណាលោតផ្លោះ

Hypermarket ទីផ្សារដែលមានការផ្លាស់ប្តូរនូវតម្លៃយ៉ាងឆាប់រហ័ស

## I

I Owe You (IOU) ខ្ញុំជំពាក់អ្នក

Idealized Condition ល័ក្ខខ័ណ្ឌក្រឹត្យភាព

Identification (ID) អត្តសញ្ញាណប័ណ្ណ

Ideology មនោគមវិជ្ជា

Idle capital ទុនទុកចោល ទុនក្រៅចលនា

Idle Machinery គ្រឿងយន្តមិនដំណើរការ

Illegal contract កិច្ចសន្យាមិនស្របច្បាប់

Illegal Trade ពាណិជ្ជកម្មខុសច្បាប់ មិនស្របច្បាប់

Immediate Objective ទិសដៅបន្ទាន់

Immediate Payment ការទូទាត់ភ្លាមៗ

Immigration and Naturalization Service (INS)
ក្រសួងអន្តោប្រវេសន៍និងផ្លាស់ប្តូរ សញ្ជាតិរបស់សហរដ្ឋអាមេរិក

Immunity អភ័យឯកសិទ្ធិ

Implementation of Agreement ការអនុវត្តន៍កិច្ចព្រមព្រៀង

Implementation of Law ការអនុវត្តច្បាប់

Import Duty ពន្ធនាំចូល

Import License = Import Permit អាជ្ញាប័ណ្ណនាំចូល

Import Permit អាជ្ញាប័ណ្ណនាំចូល

Import Quota កូតាការនាំចេញ

Import Surcharge ការយកពន្ធនាំចូលហួសពីច្បាប់កំណត់

Import-Export Company ក្រុមហ៊ុនអាហរ័ណ - នីហរ័ណ

Impost ពន្ធលើទំនិញនាំចូល

Impoundment ការឃាត់ចាប់ទុក (រថយន្ត, ទូក)

Imprest Account គណនីបុរេប្រទាន

Improvement ការកែលំអ, សុវុឌ្ឍិកម្ម

In Good Faith ដោយស្មោះត្រង់

Inappropriate Aid ជំនួយមិនសមស្រប

Incentive Bonus (Payment) ប្រាក់បន្ថែមពិសេសលើកទឹកចិត្ត

Incentive Measure វិធានការលើកទឹកចិត្ត

Incentive Package ចង្កោម (កញ្ចប់) លើកទឹកចិត្ត

Incentive Scheme ផែនការលើកទឹកចិត្តក្នុងការងារ

Incidence of Tax បន្ទុកពន្ធ

Inclusion List (IL) បញ្ជីដាក់បញ្ចូល

គឺជាបញ្ជីដែលប្រទេសជាសមាជិកអាស៊ានដាក់បញ្ចូលនូវបណ្តាបន្ទាត់ពន្ធ (tariff lines) នៃទំនិញដែលត្រូវ កាត់បន្ថយពន្ធស្របតាមកិច្ចព្រមព្រៀង CEPT/AFTA

Inclusive Saving សន្សំសរុប, សញ្ជ័យសរុប

Income Per Capita ចំណូលក្នុងម្នាក់ៗ

Income Tax ពន្ធលើប្រាក់ចំណូល

Income-Outlay Accounts គណនីចំណូលចំណាយ

Inconvertible Currency រូបិយប័ណ្ណដែលមិនអាចដូរយករូបិយប័ណ្ណដទៃទៀតបាន

Increase in Price ការតំឡើងថ្លៃ

Increase in Size កំណើនបរិមាណ

Increasing Profits ប្រាក់ចំណេញដែលកាន់តែកើនឡើង

Independence ឯករាជ្យភាព

Independent Assessment Team (IAT) ក្រុមវាយតម្លៃដោយឯករាជ្យ

India Technical and Economic Cooperation (ITEC)
កិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ចបច្ចេកទេសឥណ្ឌា

India-ASEAN Economic Cooperation Committee (IAECC)
គណៈកម្មាធិការ សហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន-ឥណ្ឌា

Indirect Cost ចំណាយប្រយោល

Indirect Tax ពន្ធប្រយោល ពន្ធមិនចំពោះ

Indirect Taxation ការយកពន្ធប្រយោល

Individual Action Plan (IAP) ផែនការសកម្មភាពដោយឡែករបស់បុគ្គល

Individual Retirement Account (IRA) កុងធនាគារបុគ្គលសំរាប់រីរត្រៃ

Indochina Economic Zone (IEZ) តំបន់សេដ្ឋកិច្ចឥណ្ឌូចិន

Indonesia-Malaysia-Philippines East ASEAN Growth Area
ទំបន់ រីកលូតលាស់រួមមាន ឥណ្ឌូនេស៊ុី ម៉ាឡេស៊ុី ហ្វីលីពិន អាស៊ានខាងកើត

Indonesia-Malaysia-Singapore Growth Triangle (IMS-GT)
តំបន់ត្រីកោណ រីកលូតលាស់រួមមាន ឥណ្ឌូនេស៊ុី ម៉ាឡេស៊ុី និង សឹង្ហបូរី

Indonesia-Malaysia-Thailand Growth Triangle (IMT-GT)
តំបន់អភិវឌ្ឍន៍ ត្រីកោណឥណ្ឌូណេស៊ុី-ម៉ាឡេស៊ុី-ថៃឡង់

Inducement បច្ច័យ (បញ្ចុកបស៊ី)

Industrial Center មជ្ឈមណ្ឌលឧស្សាហកម្ម

Industrial Development Certificate (IDC) សញ្ញាប័ត្រអភិវឌ្ឍន៍ឧស្សាហកម្ម

Industrial Economics សេដ្ឋសាស្ត្រឧស្សាហកម្ម

Industrial Estate (Park) តំបន់ឧស្សាហកម្ម

Industrial Standards and Quality Assurance Program (ISQAP)
កម្មវិធីធានា រ៉ាប់រងគុណភាព និងស្តង់ដារផ្នែកឧស្សាហកម្ម

Industrial Zone តំបន់ឧស្សាហកម្ម

Industrialization ឧស្សាហូបនីយកម្ម

Industrially Advanced Countries (IACs)
បណ្តាប្រទេសជឿនលឿនផ្នែក ឧស្សាហកម្ម

Infant Mortality អាត្រាមរណៈទារក

Inflammable Goods ទំនិញដែលអាចឆេះរហ័ស

Inflation Accounting គណនេយ្យអតិផរណា

Inflation Factor កត្តាអតិផរណា

Inflation Gap គំលាតអតិផរណា

Inflation Rate អត្រាអតិផរណា

Inflow of Goods ការហូរចូលនៃទំនិញ

Inflow of Investment ការហូរចូលវិនិយោគបរទេស

Influence ឥទ្ធិពល

Influx ការហូរចូល

Information and Communication Technology (ICT)
បច្ចេកវិជ្ជាពត៌មាននិងទំនាក់ទំនង

Information and Communication Technology for Sustainable Development (ICTSD)
បច្ចេកវិទ្យាពត៌មាន និងទូរគមនាគមន៍សំរាប់ ការអភិវឌ្ឍន៍ប្រកបដោយចីរភាព

Information and Resource Center (IRC) មជ្ឈមណ្ឌលពត៌មាននិងធនធាន

Information Science ពត៌មានវិទ្យា

Information Technology (IT) បច្ចេកវិទ្យាពត៌មាន

Information Technology Agreement (ITA) កិច្ចព្រមព្រៀងបច្ចេកវិទ្យាពត៌មាន

Information Technology Systems ប្រព័ន្ធបច្ចេកវិទ្យាពត៌មាន

Infrastructure ហេដ្ឋារចនាសម្ព័ន្ធ

Initial Price ថ្លៃដំបូង

Initial Sales ការលក់ទំនិញដំបូង

Initiative គំនិតផ្តួចផ្តើម

Input Tax ពន្ធបន្ថែមលើទំនិញ ឬ សេវារបស់ក្រុមហ៊ុន

Inquiry ការតាមដាន

Inspection Certificate វិញ្ញាបនប័ត្រត្រួតពិនិត្យ

Instability អស្ថេរភាព

Installment Sales ការលក់ជាដំណាក់ៗ

Installment Shipment ការប្រគល់ទំនិញជាដំណាក់ៗ

Installment System ប្រព័ន្ធទូទាត់បណ្តើរៗ

Institute of Development Studies (IDS) គ្រឹះស្ថានសិក្សាអភិវឌ្ឍន៍

Institute of Southeast Asia Studies (ISEAS)
វិទ្យាស្ថានសិក្សាស្រាវជ្រាវ អាស៊ីអាគ្នេយ៍ (មានទីតាំងនៅសឹង្ហបូរី)

Institute of Strategic and International Studies (ISIS) *(see also ASEAN-ISIS)*
វិទ្យាស្ថានសិក្សាស្រាវជ្រាវ យុទ្ធសាស្ត្រ និងអន្តរជាតិ

Institution ស្ថាប័ន, គ្រឹះស្ថាន

Institutionalized Mechanism យន្តការតែងតាំង

Instruction សេចក្តីណែនាំ

Instrument of Accession លិខិតុបករណ៍ចូលរួម
គឺជាឯកសារមានតំលៃគតិយុត្តិ ដែលជាទូទៅអនុម័ត ដោយសភាជាតិ (យោងតាមនីតិវិធីធម្មនុញ្ញរបស់ប្រទេស នីមួយៗ) ដែលបញ្ជាក់ និងប្រកាសទទួលស្គាល់ជាផ្លូវការ ស្តីអំពីការចូលរួមរបស់ប្រទេសនោះទៅក្នុងសន្ធិសញ្ញា ឬ កិច្ចព្រមព្រៀងអន្តរជាតិនានាដែលប្រទេសនោះពុំមែនជា ប្រទេសម្ចាស់ហត្ថលេខី

Instrument of Ratification លិខិតុបករណ៍ផ្តល់សច្ចាប័ន
គឺជាឯកសារមានតំលៃគតិយុត្តិ ដែលជាទូទៅអនុម័ត ដោយសភាជាតិ (អាស្រ័យទៅតាមនីតិវិធីធម្មនុញ្ញរបស់ ប្រទេសនីមួយៗ) ដែលចេញបញ្ជាក់ទៅលើសន្ធិសញ្ញា (treaty) ឬ កិច្ចព្រមព្រៀងអន្តរជាតិនានា (international agreements) ដែលប្រទេសនោះជាប្រទេសម្ចាស់ហត្ថលេខា original signatory state)

Insurance and Freight Cost ថ្លៃធានារ៉ាប់រង និង ថ្លៃដឹកជញ្ជូន

Intangible Assets ទ្រព្យអរូបីយ

Integrated Economic Department Areas (KAPET)
សមាហរណកម្មវិស័យក្រសួងសេដ្ឋកិច្ច

Integrated Implementation Plan (IIP) សមាហរណកម្មផែនការអនុវត្ត

Integrated Pest Management (IPM) សមាហរណកម្មគ្រប់គ្រងសត្វចង្រៃ

Integrated Work Programme on Civil Aviation and Related Services (IWPCAR)
កម្មវិធីការងារសមាហរណកម្មស្តីពី អាកាសចរណស៍ុីវិល និងសេវាទាក់ទង (អង្គការមិនមែនរដ្ឋាភិបាលអាស៊ាន បញ្ចូលជាផ្លូវការដោយ គណៈកម្មាធិការអចិន្ត្រៃយ៍អាស៊ានទី១៤ នាថ្ងៃ២១ ខែឧសភា ឆ្នាំ១៩៨១)

Integrated Work Programme on Land Transportation (IWPLT)
កម្មវិធី ការងារសមាហរណកម្ម ស្តីពីការដឹកជញ្ជូនជើងគោក

Integrated Work Programme on Shipping (IWPS)
កម្មវិធីការងារសមាហរណកម្ម ស្តីពីការដឹកជញ្ជូនតាមនាវា

Integrated Work Programme on Transportation and Communication (IWPTC)
កម្មវិធីការងារសមាហរណកម្ម ស្តីពីការដឹកជញ្ជូន និង គមនាគមន៍ ។

Integration សមាហរណកម្ម

Intellectual Property Policy Exchange (IPPE) នយោបាយផ្លាស់ប្តូរទ្រព្យបញ្ញា

Intellectual Property Rights(IPR) រក្សាសិទ្ធិ ទ្រព្យបញ្ញា
ច្បាប់ស្តីពីកម្មសិទ្ធិខាងបញ្ញា អនុលោមតាមច្បាប់នេះ គ្រប់ស្នាដៃរួមមានសៀវភៅ លទ្ធផលនៃការស្រាវជ្រាវផ្សេងៗ ត្រូវស្ថិតនៅក្រោមការ ការពារយ៉ាងត្រឹមត្រូវដោយច្បាប់ គឺបើសិនជាគ្មានការ អនុញ្ញាតពីម្ចាស់កម្មសិទ្ធិ

អ្នកដទៃពុំអាចប្រើប្រាស់ឯកសារ ឬ លទ្ធផលនៃការស្រាវជ្រាវទាំងនោះសំរាប់ធ្វើ អាជីវកម្មបានទេ ។ ច្បាប់នេះត្រូវតែ អនុវត្តន៍យ៉ាងទូលំទូលាយនៅក្នុងប្រទេសអភិវឌ្ឍន៏។ តែផ្ទុយទៅវិញវាពុំត្រូវ បានគេគោរពប៉ុន្មានទេនៅក្នុងបណ្តាប្រទេសកំពុង អភិវឌ្ឍន៏។ មូលហេតុសំខាន់ៗ នៃការពុំសូវ អនុវត្តន៏ច្បាប់ នេះនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៏ គឺដោយសារបណ្តាប្រទេសទាំងនោះពុំសូវមានអ្នកប្រាជ្ញ និងថវិកាគ្រប់គ្រាន់សំរាប់ចំណាយលើការស្រាវជ្រាវ និង ម្យ៉ាងទៀតប្រជាជនមានកំរិតជីវភាពទាបដែលពុំអាចមានលទ្ធភាពប្រើប្រាស់សៀវភៅស្នាដៃសិល្បៈ ឬលទ្ធផលនៃរបបគំហើញផ្សេងៗដែលមានតំលៃខ្ពស់បាន។

Intelligence Exchange ការប្តូរពត៏មានសំងាត់

Inter-ASEAN Industrial Investment (IAII)

វិនិយោគផ្នែកឧស្សាហកម្ម រវាង បណ្តាប្រទេសអាស៊ាន និងប្រទេសដទៃ

Inter-ASEAN Technical Exchange Programme (IATEP)

កម្មវិធីផ្លាស់ប្តូរ បច្ចេកទេសរវាងបណ្តាប្រទេសអាស៊ាន និងប្រទេសដទៃ (កិច្ចសហប្រតិបត្តិការជប៉ុន-អាស៊ាន)

Interchange of Commodities ការដោះដូរទំនិញគ្នា

Inter-Country Programme (ICP) កម្មវិធីរវាងប្រទេស និង ប្រទេសដទៃ

Interest Rate for Savings អត្រាការប្រាក់សន្សំ

Interest Rate on Loans អត្រាការប្រាក់ខ្ចី

Interest Rate Risk គ្រោះអត្រាការប្រាក់ ហានិភ័យនៃអត្រាការប្រាក់

Interference ការជ្រៀតជ្រែក

Inter-Governmental Maritime Consultative Organization (IMCO)
អង្គការពិគ្រោះយោបល់អន្តររដ្ឋាភិបាលផ្នែកសមុទ្រ

Inter-Governmental Organization (IGO)
អង្គការអន្តររដ្ឋាភិបាល (សូមមើល
សេចក្តីថ្លែងការណ៍រួមបន្ទាប់ពីកិច្ចប្រជុំកំពូល នាទីក្រុង ម៉ានីល ខែធ្នូ ឆ្នាំ១៩៨៧)

Interim Technical Secretariat (IST) រដ្ឋលេខាធិការស្តីទីបច្ចេកវិជ្ជា

Inter-Institutional Linkage Programme (IILP)
កម្មវិធីភ្ជាប់រវាងស្ថាប័នមួយទៅស្ថាប័នមួយទៀត

Inter-Institutional Linkages Program (IILP) កម្មវិធីទំនាក់ទំនងអន្តរស្ថាប័ន

Intermediary Projects គំរោងការថ្នាក់កណ្តាល

Intermediate Goods and Services ទំនិញ និង សេវាបន្ទាន់

Intermediate Range Nuclear (INF) អាវុធនុយក្លេអ៊ែធុនកណ្តាល

Intermediate Technology បច្ចេកវិទ្យាថ្នាក់កណ្តាល (បច្ចេកវិទ្យាថ្នាក់មធ្យម)

Internal Coordination Network (ICN) បណ្តាញសំរបសំរួលផ្ទៃក្នុង

Internal Taxes អាករក្នុងស្រុក

Internal Trade ពាណិជ្ជកម្មក្នុងប្រទេស

International Action Against Hunger (Action International Centre la Faim)
សកម្មភាពអន្តរជាតិប្រឆាំងនឹងការអត់ឃ្លាន

International Air Transport Association (IATA)
សមាគមន៍ដឹកជញ្ជូនផ្លូវអាកាស អន្តរជាតិ
International Arena ឆាកអន្តរជាតិ
International Association of Peacekeeping Training Centres (IAPTC)
មជ្ឈមណ្ឌលសមាគមអន្តរជាតិក្នុងការបណ្តុះបណ្តាល ថែរក្សាសន្តិភាព
International Atomic Energy Agency (IAEA) ទីភ្នាក់ងារថាមពលអាតូមិចអន្តរជាតិ
International Bank for Reconstruction and Development (IBRD)
ធនាគារ អន្តរជាតិសំរាប់ស្តារ និងអភិវឌ្ឍន៍ (ធនាគារពិភពលោក)
International Center for Living Aquatic Resources Management (ICLARM)
មជ្ឈមណ្ឌលអន្តរជាតិសំរាប់គ្រប់គ្រងធនធាន ដែលរស់ក្នុងទឹក
International Center for Settlement of Investment Disputes (ICSID)
មជ្ឈមណ្ឌលអន្តរជាតិដើម្បីដោះស្រាយជម្លោះ អំពីការវិនិយោគទុន
International Chamber of Commerce (ICC) សភាពាណិជ្ជកម្មអន្តរជាតិ
International Civil Aviation Organization (ICAO)
អង្គការអាកាសចរណ៍ ស៊ីវិលអន្តរជាតិ
International Committee for Reconstruction of Cambodia (ICORC)
គណៈកម្មាធិការអន្តរជាតិដើម្បីកសាងកម្ពុជា
International Committee for the Red Cross and Red Crescent Societies (ICRC)
គណៈកម្មាធិការ កាកបាទក្រហមអន្តរជាតិ និងសង្គមព្រះច័ន្ទក្រហម
International Committee of the Red Cross (ICRC)
គណៈកម្មាធិការអន្តរជាតិ កាកបាទក្រហម
International Convention for the Settlement of Investment Disputes
សន្និបាតអន្តរជាតិដើម្បីដោះស្រាយជម្លោះ ការវិនិយោគទុន
International Cooperation (IC) សហប្រតិបត្តិការអន្តរជាតិ
International Coordination Network (ICN) បណ្តាញសំរបសំរួលអន្តរជាតិ

International Court of Justice Association (IDA)
សមាគមតុលាការយុត្តិធម៌ អន្តរជាតិ
International Decade for Natural Disaster Reduction (IDNDR)
ទសវត្សអន្តរជាតិដើម្បីកាត់បន្ថយគ្រោះធម្មជាតិ
International Development Enterprises Association (IDEA)
សមាគមសហគ្រាសអភិវឌ្ឍន៍អន្តរជាតិ
International Development Program (IDP) កម្មវិធីអភិវឌ្ឍន៍អន្តរជាតិ
International Development Research Center (IDRC)
មជ្ឈមណ្ឌលស្រាវជ្រាវ អភិវឌ្ឍន៍អន្តរជាតិ
International Electro-Technical Commission (IEC)
គណៈកម្មាការបច្ចេកវិជ្ជាអគ្គិសនីអន្តរជាតិ
International English Language Testing System (IELTS)
ប្រព័ន្ធប្រឡងភាសាអង់គ្លេសអន្តរជាតិ
International Federation of Red Cross and Red Crescent Societies (IFRC)
សហព័ន្ធកាកបាទក្រហមអន្តរជាតិ និងសង្គមព្រះច័ន្ទក្រហម
International Finance Corporation សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ
International Financial Institutions (IFIs) បណ្ដាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ
International Football Federation Association (FIFA)
សមាគមសហព័ន្ធ បាល់ទាត់អន្តរជាតិ
International Force in East Timor (INTERFET)
កងកំលាំងអន្តរជាតិនៅទីម័រខាងកើត
International Fund for Agricultural Development (IFAD)
មូលនិធិអន្តរជាតិសំរាប់ការអភិវឌ្ឍន៍កសិកម្ម
International Health Program (IHP) កម្មវិធីសុខមាលភាពអន្តរជាតិ
International Labour Organization (ILO) អង្គការពលកម្មអន្តរជាតិ
International Law ច្បាប់អន្តរជាតិ

International Maritime Organization (IMO) អង្គការនាវាចរណ៍អន្តរជាតិ

International Monetary Fund (IMF) មូលនិធិរូបិយវត្ថុអន្តរជាតិ

International Natural Rubber Agreement (INRA)
កិច្ចព្រមព្រៀងកៅស៊ូធម្មជាតិអន្តរជាតិ

International Organization (IO) អង្គការអន្តរជាតិ

International Organization Department (IOD) ក្រសួងអង្គការអន្តរជាតិ

International Organization for Migration (IOM)
អង្គការអន្តោប្រវេសន៍ អន្តរជាតិ

International Police (INTERPOL) ប៉ូលីសអន្តរជាតិ

International Politics នយោបាយអន្តរជាតិ

International Price Index សន្ទស្សន៍ថ្លៃអន្តរជាតិ

International Production System ប្រព័ន្ធផលិតកម្មអន្តរជាតិ

International Relations ទំនាក់ទំនងអន្តរជាតិ

International Rescue Committee (IRC) គណៈកម្មាធិការសង្គ្រោះអន្តរជាតិ

International Rice Research Institute (IRRI) វិទ្យាស្ថានស្រាវជ្រាវស្រូវអង្គអន្តរជាតិ

International Safety Management (ISM) ការគ្រប់គ្រងសុវត្ថិភាពអន្តរជាតិ

International Standard Book Number (ISBN)
ការចុះលេខសៀវភៅតាមខ្នាតអន្តរជាតិ

International Standard Industrial Classification (ISIC)
ការបែងចែកឧស្សាហកម្មតាមខ្នាតអន្តរជាតិ

International Standard Organization (ISO) អង្គការខ្នាតគំរូអន្តរជាតិ

International Standard Serials Number (ISSN) លេខសំគាល់ខ្នាតគំរូអន្តរជាតិ

International Standard ស្តង់ដារអន្តរជាតិ

International System of Units ប្រព័ន្ធឯកតាអន្តរជាតិ

International Systems ប្រព័ន្ធអន្តរជាតិ

International Telecommunication Union (ITU) សហព័ន្ធខាងទំនាក់ទំនងអន្តរជាតិ

International Tendering ការដាក់អោយដេញថ្លៃជាអន្តរជាតិ

International Timber Trade Organization (ITTO) អង្គការពាណិជ្ជកម្មឈើអន្តរជាតិ

International Trade Center (ITC) មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ

ITC ជាអង្គភាពឯករាជ្យរបស់អង្គការសហប្រជាជាតិ
ដែលមានទីតាំងនៅ Geneva ប្រទេសស្វីស
អង្គភាពនេះមានតួនាទីផ្តល់នូវការ
រៀបចំជំនួយបច្ចេកទេសសំរាប់បណ្តាប្រទេសអភិវឌ្ឍន៍តិចតួច
លើការអភិវឌ្ឍន៍ និង ជំរុញសក្តានុពលដល់ការនាំចេញ ។

International Trade Organization (ITO) អង្គការពាណិជ្ជកម្មអន្តរជាតិ

International Trade Secretariats (ITSs) លេខាធិការដ្ឋានពាណិជ្ជកម្មអន្តរជាតិ

International Trade ពាណិជ្ជកម្មអន្តរជាតិ

International Union for Conservation of Nature and Natural Resources (IUC)
សហភាពអន្តរជាតិសំរាប់រក្សាធម្មជាតិ និងធនធាន ធម្មជាតិ

International Women's Development Agency (IWDA)
ទីភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីអន្តរជាតិ

Inter-Sessional Meeting (ISM) សម័យប្រជុំ ពីផ្នែកមួយទៅផ្នែកមួយ

Inter-Sessional Support Group (ISG) ក្រុមគាំទ្រសម័យប្រជុំពីផ្នែកមួយទៅផ្នែកមួយ

Inter-Sessional Support Group on Confidence Building Measures
ក្រុមគាំទ្រសម័យប្រជុំពីផ្នែកមួយទៅផ្នែកមួយ
ស្តីពីវិធានការកសាងជំនឿទុកចិត្ត

er-Sessional Support Group on Disaster Relief (ISG on DR)
ក្រុមគាំទ្រសម័យប្រជុំពីផ្នែកមួយទៅផ្នែកមួយ
ស្តីពីការជួយសង្គ្រោះគ្រោះមហន្តរាយ

ervention ការជ្រៀតជ្រែក, អន្តរាគមន៍

a Bloc Cooperation in Investment and Trade
សហប្រតិបត្តិការក្នុងការវិនិយោគនិងពាណិជ្ជកម្មក្នុងតំបន់

a-ASEAN Trade ពាណិជ្ជកម្មក្នុងរង្វង់អាស៊ាន

ពាណិជ្ជកម្មគឺជាកិច្ចសហប្រតិបត្តិការមួយយ៉ាងសំខាន់ របស់អាស៊ាន។ ដើម្បីបង្កើតនូវពាណិជ្ជកម្មក្នុងរង្វង់អាស៊ាន ប្រទេសជាសមាជិកបានចុះកិច្ចព្រមព្រៀង ស្តីពីការអនុគ្រោះ ពន្ធគយរួម សំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន។ គោលដៅដ៏ចំបងនៃកិច្ចព្រមព្រៀងនេះ គឺលុបបំបាត់នូវបណ្តាឧបសគ្គនានាដែលរួមមានរបាំងពន្ធគយ និង របាំងមិនមែនពន្ធគយដែលរារាំងដល់សកម្មភាព ពាណិជ្ជកម្មរវាងប្រទេសសមាជិកអាស៊ាន។ នាពេលបច្ចុប្បន្ន ពាណិជ្ជកម្មក្នុងរង្វង់អាស៊ានមានប្រមាណ ២០% នៃសកម្មភាពពាណិជ្ជកម្មអន្តរជាតិរបស់អាស៊ាន ។

ested Capital ទុនវិនិយោគ

estment Allowance វិភាជន៍បណ្តាក់ទុន ប្រាក់ឧបត្ថម្ភដល់វិនិយោគ

estment and Trade Promotion Program (TIPP)
កម្មវិធីជំរុញពាណិជ្ជកម្ម និង វិនិយោគ

estment Expenditure ចំណាយវិនិយោគ

Investment Goods ទំនិញសំរាប់ការវិនិយោគ

Investment Guarantee Agreements (IGAs) កិច្ចព្រមព្រៀងធានារ៉ាប់រងខាងវិនិយោគ

Investment in Industry (3I) វិនិយោគក្នុងផ្នែកឧស្សាហកម្ម

Investment Incentives ការលើកទឹកចិត្តវិនិយោគ

Investment Licence លិខិតអនុញ្ញាត្តិអោយវិនិយោគ អាជ្ញាប័ណ្ណវិនិយោគ

Investment Procedures នីតិវិធីនៃការវិនិយោគ

Investment Promotion ការជំរុញវិនិយោគ

Investment Saving-Liquidity/Money (IS-LM)
វិនិយោគប្រាក់សន្សំនិងប្រាក់អាចដកចេញបាន

Investment Tax Allowance (ITA) ការអនុញ្ញាត្តិពន្ធលើផ្នែកវិនិយោគ

Investment Trust = Investment Company ក្រុមហ៊ុនវិនិយោគ

Investment Turnover ផលចំណេញដែលបានមកពីការបណ្តាក់ទុន

Invisible Earning ចំណូលអរូបិយ

Invisible Hand ដៃអរូបិយ

Isolation ភាពឯកកោ

Issuance of Certificate of Origin ការចេញវិញ្ញាប័ត្រដើមកំណើតទំនិញ

Item of Expenditure មុខចំណាយ

## J

Jakarta Informal Meeting (JIM)
កិច្ចប្រជុំក្រៅផ្លូវការនៅទីក្រុងហ្សាការតា
(កិច្ចប្រជុំដើម្បីដោះស្រាយជំលោះនៅប្រទេសកម្ពុជា)

Japan International Cooperation Agency (JICA)
ទីភ្នាក់ងារ សហប្រតិបត្តិការ អន្តរជាតិជប៉ុន

Japan International Cooperation Center (JICC)
មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិជប៉ុន

Japan International Volunteer Center (JIVC) មជ្ឈមណ្ឌលស្ម័គ្រចិត្តជប៉ុន អន្តរជាតិ

Japan Overseas Cooperation Volunteers (JOCV)
សហប្រតិបត្តិការអ្នកស្ម័គ្រចិត្តក្រៅប្រទេសនៃប្រទេសជប៉ុន

Japan Pharmaceutical Manufacturer Association (JPMA)
សមាគមអ្នកផលិតឱសថរបស់ជប៉ុន

Japan Red Cross Society (JRCS) សង្គមកាកបាទក្រហមជប៉ុន

Japan Scholarship Funds (JSF) មូលនិធិអាហារូបករណ៍ជប៉ុន

Japan Sotoshu Relief Committee (JSRC)
គណៈកម្មាធិការជួយសង្គ្រោះ សូតូស៊ូជប៉ុន

Japan-ASEAN Comprehensive Exchange Programme (JACEP)
កម្មវិធីផ្លាស់ប្តូរគ្រប់វិស័យរវាងអាស៊ាន-ជប៉ុន (ការស្នើនូវកម្មវិធីនេះ
បានលើកឡើងដោយនាយករដ្ឋមន្ត្រី ជប៉ុន ណូបូ តាកេហ្សិតា
ក្នុងកិច្ចប្រជុំកំពូលនៅ ទីក្រុងម៉ានីល
ក្នុងគោលបំណងជំរុញការផ្លាស់ប្តូរផ្នែកវប្បធម៌រវាង អាស៊ាន-ជប៉ុន)

Japan-ASEAN Co-operation Promotion Programme (JACPP)
កម្មវិធីជំរុញ កិច្ចសហប្រតិបត្តិការ អាស៊ាន_ជប៉ុន

Japan-ASEAN Exchange Program (JAEP) កម្មវិធីនៃការផ្លាស់ប្តូរ អាស៊ាន-ជប៉ុន

Japan-ASEAN Exchange Projects (JAEP) គំរោងផ្លាស់ប្តូរជប៉ុន-អាស៊ាន

Japan-ASEAN Investment Company (JAIC) ក្រុមហ៊ុនវិនិយោគជប៉ុន-អាស៊ាន

Japan-China Relations (JRC) ទំនាក់ទំនងជប៉ុន-ចិន

Japan-Russian Federation Relations (JRFR) ទំនាក់ទំនងជប៉ុននិងសហព័ន្ធរុស្ស៊ី

Japan-United States Relation (JUSR) ទំនាក់ទំនងជប៉ុន-អាមេរិក

Job Centre មជ្ឈមណ្ឌលការងារ

Job Lot ទំនិញចាស់ៗលក់ថោកៗ

Joint Account គណនីរួមគ្នា

Joint Ad Hoc Working Group on Shipping (JAHWGS)
ក្រុមការងារចំរុះ អាដហុកផ្នែកដឹកជញ្ជូនតាមនាវា

Joint Commission (JC) គណៈកម្មាការចំរុះ ឬ គណៈកម្មាការរួម

Joint Committee គណៈកម្មាធិការចំរុះ

Joint Consultive Meeting (JCM) កិច្ចប្រជុំពិភាក្សារួម.កិច្ចប្រជុំពិគ្រោះ

Joint Cooperation Committee (JCC)
គណៈកម្មាធិការសហប្រតិបត្តិការចំរុះ (ភាពជាដៃគូរវាងអាស៊ាន និងសហគមន៍សេដ្ឋកិច្ចអឺរ៉ុប)

Joint Development Area (JDA) តំបន់អភិវឌ្ឍន៍ចំរុះ ឬ តំបន់អភិវឌ្ឍន៍រួម

Joint Economic Committee (JEC) គណៈកម្មាធិការសេដ្ឋកិច្ចរួម

Joint Investment Committee (JIC)
គណៈកម្មាធិការវិនិយោគចំរុះ គណៈកម្មាធិការនេះ បានបង្កើតដោយ AEMក្នុងគោលបំណងបង្កើន
វិនិយោគឯកជនពីប្រទេសអឺរ៉ុបមកក្នុងប្រទេសសមាជិក អាស៊ាន។

Joint Management ការគ្រប់គ្រងរួមគ្នា

Joint Military Exercise សមយុទ្ធយោធារួម

Joint Ministerial Meeting (JMM) កិច្ចប្រជុំរួមថ្នាក់រដ្ឋមន្ត្រី (រដ្ឋមន្ត្រី ការបរទេស និងរដ្ឋមន្ត្រីសេដ្ឋកិច្ច) កិច្ចប្រជុំនេះត្រូវបាន បង្កើតឡើងដោយសន្និសីទកំពូលនាទទីក្រុងម៉ានីល ឆ្នាំ១៩៨៧។ កិច្ចប្រជុំ JMM ធ្វើឡើងនៅពេលចាំបាច់ដើម្បី ជួយសម្រួល ការសំរបសំរួលវិស័យមួយទៅវិស័យមួយ និង ដើម្បីពិគ្រោះយោបល់គ្នាស្តីពីសកម្មភាពអាស៊ាន។ កិច្ចប្រជុំ រួមថ្នាក់រដ្ឋមន្ត្រី រួមមានរដ្ឋមន្ត្រីការបរទេស និងរដ្ឋមន្ត្រី សេដ្ឋកិច្ចអាស៊ាន នៅក្រោមអធិបតីភាពរួមរបស់ប្រធាន AMM និង AEM ។ កិច្ចប្រជុំនេះ អាចត្រូវផ្តួចផ្តើមគំនិត ដោយរដ្ឋមន្ត្រីការបរទេស ឬរដ្ឋមន្ត្រីសេដ្ឋកិច្ច។ តាមធម្មតា JMM ជួបប្រជុំមុនសន្និសីទកំពូលរបស់អាស៊ាន ។

Joint Monitoring Committee (JMC) គណៈកម្មាធិការត្រួតពិនិត្យរួម

Joint Owner ម្ចាស់កម្មសិទ្ធិរួមគ្នា

Joint Ownership កម្មសិទ្ធិរួមគ្នា

Joint Pharmaceutical Manufacturing Association (JPMA) សមាគមអ្នកផលិត ឱសថរួមគ្នា

Joint Planning and Management Committee (JPMC) គណៈកម្មាធិការចំរុះ រៀបចំផែនការ និងគ្រប់គ្រង

Joint Planning and Monitoring Committee (JPMC) គណៈកម្មាធិការត្រួតពិនិត្យនិងផែនការរួម

Joint Planning Committee (JPC) គណៈកម្មាធិការផែនការរួម

Joint Planning Committee to the Sub-Committee (JPC-SC) គណៈកម្មាធិការ ចំរុះ ដើម្បីរៀបចំផែនការសំរាប់អនុគណៈកម្មាធិការ

Joint Science and Technology Committee (JSTC) គណៈកម្មាធិការ វិទ្យាសាស្ត្រ និង បច្ចេកទេសរួម

Joint Standing on Commerce, Industry and Banking (JSCCIB)
គណៈកម្មាធិការអចិន្ត្រៃយ៍ចំរុះ ផ្នែកពាណិជ្ជកម្ម ឧស្សាហកម្ម និង ធនាគារ

Joint Stock Bank ធនាគារភាគហ៊ុនរួម

Joint Stock Company ក្រុមហ៊ុនភាគហ៊ុនរួម

Joint Study Group (JSG) ក្រុមសិក្សារួមគ្នា

Joint Study Group on ASEAN-Japan Cultural Co-operation (JSGCC)
ក្រុមសិក្សារួម អំពីសហប្រតិបត្តិការវប្បធម៌រវាង អាស៊ាន និង ជប៉ុន

Joint Trade Study Group (JTSG) ក្រុមសិក្សាពាណិជ្ជកម្មរួម

Joint Trade Study Group ASEAN-New Zealand (JTSG)
ក្រុមសិក្សារួម អំពីបញ្ហាពាណិជ្ជកម្ម អាស៊ាន-នូវែលហ្សេឡង់

Joint Venture Enterprise សហគ្រាសអាជីវកម្មចំរុះ

Joint Venture អាជីវកម្មរួមគ្នា

ជាទំរង់មួយនៃការវិនិយោគផ្ទាល់បរទេស គឺជាទំនាក់ទំនងបញ្ចូលគ្នានូវធនធានបច្ចេកទេស បទពិសោធន៍ការ គ្រប់គ្រង ការចែករំលែកនៃហានិភ័យ និងជាការបង្កើតឡើងនូវអង្គភាពស្របច្បាប់ ដើម្បីសំរេចគោលដៅជាក់លាក់ បណ្តាភាគីទាំងអស់ដែលចូលរួម។ អាជីវកម្មរួមគ្នា គឺជាយុទ្ធសាស្ត្រឈានចូលក្នុងទីផ្សារមួយដែលអាចបន្ថយនូវកំរិតគ្រោះថ្នាក់ខ្ពស់ និងច្រើនតែទទួលបានជោគជ័យ។ ម្យ៉ាងទៀតអាជីវកម្មរួមគ្នាក៏ជាយុទ្ធសាស្ត្រនៃការកាត់បន្ថយទាំងកំរិតហានិភ័យ ចំពោះសេដ្ឋកិច្ច និង នយោបាយ ដោយផ្សារភ្ជាប់ជាមួយនឹងប្រទេសដែលទទួលយកនូវ ចំណេះដឹង

ជំនាញ និង ប្រព័ន្ធទីផ្សាររបស់ក្រុមហ៊ុនក្នុង ស្រុកជាមូលធន និង បច្ចេកវិជ្ជារបស់ក្រុមហ៊ុនបរទេស ។

Judicial Processes ដំណើរការច្បាប់

Juridical Person នីតិបុគ្គល

Jurisdiction យុត្តធិការ

## K

Keep It Short and Simple (KISS) ធ្វើអោយខ្លី ហើយងាយស្រួល

Khmer Development Intellectual Association (KDIA)
សមាគមអភិវឌ្ឍន៍បញ្ញវន្តខ្មែរ

Khmer Institute of Democracy (KID) វិទ្យាស្ថានខ្មែរនៃលិទ្ធិប្រជាធិបតេយ្យ

Khmer Journalists Association (KJA) សមាគមអ្នកកាសែតខ្មែរ

Khmer Kampuchea Krom Association (KKKA) សមាគមខ្មែរកម្ពុជាក្រោម

Khmer Kampuchea Krom Human Rights Association (KKK HRA)
សមាគមសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម

Khmer New Generation (KNG) ខ្មែរជំនាន់ក្រោយ

Khmer Press Agency (Agence Khmer de Press) (AKP) ទីភ្នាក់ងារសារពត៌មានខ្មែរ

Khmer Rural Development Organization (KRDA) អង្គការអភិវឌ្ឍន៍ជនបទខ្មែរ

Khmer Students and Intellectuals Association (KSAI)
សមាគមនិស្សិតបញ្ញវន្តខ្មែរ

Khmer Writer's Association (KWA) សមាគមអ្នកនិពន្ធខ្មែរ

Khmer Youth Development Organization (KYDO) សមាគមអភិវឌ្ឍន៍យុវជនខ្មែរ

Killing ប្រាក់ចំណេញដ៏សម្បើម ឬសំលាប់រង្គាល

Knock Down Price ថ្លៃថោកបំផុត

Knock on Effect ផលប៉ះពាល់ប្រយោល

Knock Out (KO) វាយដួល វាយអោយសន្លប់

Knock the Competition ប្រកួតប្រជែង

Know-How ចំណេះប្រតិបត្តិ

គឺជាសំណុំនៃចំណេះដឹងវិទ្យាស្ថានទាំងឡាយ រួមមានបច្ចេកវិទ្យា និង ការពិសោធន៍ស្តីពីបច្ចេកវិទ្យា និង

ផលិតកម្មនៃការសំងាត់នូវរបកគំហើញនានា។ បច្ចុប្បន្ន ចំណេះប្រតិបត្តិបង្កើតនូវមែកធាងដោយឡែក នៃទីផ្សារ អាជ្ញាប័ណ្ណ ដែលមានទំរង់ផ្ទេរៈប្តូរជាលក្ខណៈអន្តរជាតិនូវ ចំណេះប្រតិបត្តិផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា ផ្អែកទៅលើ មូលដ្ឋានពាណិជ្ជកម្ម ក្នុងបរិការណ៍ផ្តាច់មុខដោយក្រុមហ៊ុន ឯកជនធំៗ និងរដ្ឋ។

Knowledge-How

ចំណេះប្រតិបត្តិ ក្នុងរង្វង់អាសាន ព្រមទាំងជាមួយនឹងអង្គការតំបន់ដទៃទៀត នៅក្នុងពិភពលោក ។ រដ្ឋមន្ត្រីសេដ្ឋកិច្ចអាសានមានភារកិច្ច លើកឡើង និង កំណត់នូវគោលនយោបាយ និងយុទ្ធសាស្ត្រ សេដ្ឋកិច្ចព្រមទាំងតាមដានលើដំណើរការនៃការអនុវត្តន៍ នយោបាយនោះផង ។រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានជួបប្រជុំជារៀងរាល់ឆ្នាំ ហើយធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំនៃប្រទេសជាសមាជិក អាស៊ាន ។ កិច្ចប្រជុំលើកទី២៩ របស់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន បានប្រព្រឹត្តិទៅពីថ្ងៃ ទី១៦ ដល់ថ្ងៃទី ១៨ ខែតុលា ឆ្នាំ១៩៩៧ នៅទីក្រុងកូឡាឡាំពួរនៃប្រទេសម៉ាឡេស៊ី ។ គណៈប្រតិភូនៃប្រទេសកម្ពុជា ដែលដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី

Korea Peninsula (KP) ឧបទ្វីបកូរ៉េ

Korean Institute of Science and Technology (KIST)

វិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិជ្ជាកូរ៉េ

Korean International Cooperation Agency (KICA)

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ

Korean Peninsula Energy Development Organization (KEDO)
អង្គការអភិវឌ្ឍន៍ថាមពលឧបទ្វីបកូរ៉េ

Korean Peninsula Energy Organisation (KPEO) អង្គការថាមពលឧបទ្វីបកូរ៉េ

Kuala Lumpur Declaration 1971
សេចក្តីប្រកាសរួមឆ្នាំ ១៩៧១នៅកូឡាឡាំពួរ
សេចក្តីប្រកាសរួមនេះធ្វើឡើងក្នុងកិច្ចប្រជុំរបស់រដ្ឋមន្ត្រីក្រសួងការបរទេសអាស៊ាន នៅទីក្រុងកូឡាឡាំពួរនាថ្ងៃ ទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧១។ ចំណុចសំខាន់ៗក្នុងកិច្ចប្រជុំ នេះគឺ បណ្តាប្រទេសទាំង ៥ ដែលជាសមាជិកអាស៊ាន (ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបូរី ថៃឡង់ដ៍) បានធ្វើសេចក្តីថ្លែងការណ៍រួមមួយ ស្តីពីការប្រឹងប្រែងរបស់រដ្ឋាភិបាលខ្លួន ក្នុងការថែរក្សាអាស៊ីអគ្នេយ៍ជាតំបន់ សន្តិភាព សេរីភាព និង អព្យាក្រឹត្យ ដោយគ្មានការលូកដៃធ្វើអន្តរាគមន៍នៃកំលាំងមកពីខាងក្រៅ ។

Kuala Lumpur Summit (ASEAN) 1997
សន្និសីទកំពូលនៅកូឡាឡាំពួរ (អាស៊ាន) ឆ្នាំ១៩៧៧
សន្និសីទកំពូលនេះធ្វើឡើងនៅ កូឡាឡាំពួរនាថ្ងៃទី ៣-៤ ខែសីហា ឆ្នាំ១៩៧៧ ដើម្បីរំលឹកខួបលើកទី១០ នៃការបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងក៏ជាការជួបប្រជុំរបស់អ្នកដឹកនាំជាន់ខ្ពស់នៃរដ្ឋាភិបាលជាសមាជិកអាស៊ាន ដើម្បីបញ្ជាក់ឡើងវិញនូវសាមគ្គីភាព របស់អាស៊ាននៅក្នុងអាស៊ីអាគ្នេយ៍ ដែលត្រូវរង្គោះរង្គើរមួយអន្ទី ដោយសារកំលាំងបដិវត្តន៍។ ម្យ៉ាងទៀត ក្នុងជំនួបកំពូលនេះក៏បានពិនិត្យឡើងវិញដែរនូវសំណើស្តីពីសេរីភាវូបនីយកម្ម

ពាណិជ្ជកម្មក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន ដែលបានលើកឡើងនៅក្នុងជំនួបកំពូលនាទីក្រុងបាលី ហើយដែលពុំទទួលបានការឯកភាព។

## L

Labeling Department ផ្នែកបិទស្លាកលើទំនិញ

Labeling Requirements ការតំរូវអោយបិទផ្លាក

Labor Legislation = Labor Law ច្បាប់ការងារ

Labour Charges កម្រៃពលកម្ម

Labour Dispute ទំនាស់រវាងនិយោជក និង និយោជិក

Labour Force កំលាំងពលកម្ម

Labour Law ច្បាប់ពលកម្ម ឬច្បាប់ការងារ

Labour Market ទីផ្សារពលកម្ម

Labour Productivity ផលិតភាពពលកម្ម

Labour Relations ទំនាក់ទំនងរវាងនិយោជក និង និយោជិក

Labour Security សន្តិសុខពលកម្ម

Labour Shortage កង្វះខាតពលកម្ម

Labour Union សហជីព សហភាពពលកម្ម

Labour-Intensive Industry

ឧស្សាហកម្មអតិពលកម្ម គឺជាឧស្សាហកម្មដែល ប្រើកំលាំងកម្មករច្រើន ដូចជា រោងចក្រកាត់ដេរសំលៀកបំពាក់ជាដើម។

ឧស្សាហកម្មអរិពលកម្មច្រើន មានមូលដ្ឋាននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលខុសពីឧស្សាហកម្ម អតិមូលធន ឬឧស្សហកម្មអតិបច្ចេកវិទ្យា (Capital-intensive industry or hi-tech industry) ដែលជាទូទៅមានមូលដ្ឋាននៅក្នុងប្រទេស អភិវឌ្ឍន៍។

Labour-Intensive Manufacturing Sector វិស័យកម្មន្តសាលអតិពលកម្ម

Labour-Intensive Technique បច្ចេកទេសអតិពលកម្ម

Labour-Intensive អតិពលកម្ម
Lack of Balance បាត់បង់តុល្យភាព
Lack of Confidence បាត់ជំនឿ
Lame Duck ក្រុមហ៊ុនដែលមានបញ្ហាហិរញ្ញវត្ថុ
Land Based Sources Marine Pollution (LBSMP)
ការបំពុលសមុទ្រដោយប្រភពលើដី
Land Ownership កម្មសិទ្ធិដី
Land Reform ការកែទម្រង់ដីធ្លី
Land Registry ការិយាល័យសុរិយោដី
Land Tax ពន្ធដី
Land Title Department នាយកដ្ឋានសុរិយោដី
Landed Cost ថ្លៃទំនិញដល់ផែ
Landing Charge ថ្លៃដាក់ទំនិញ និងពន្ធ
Landing Order ប័ណ្ណបញ្ជាដាក់ទំនិញ
Landowner ម្ចាស់ដី
Last In, First Out (LIFO) ចូលក្រោយចេញមុន
Latin American Free Trade Association (LAFTA)
សមាគមពាណិជ្ជកម្មសេរី អាមេរិកឡាទីន
Latin American Integration Association (LAIA)
សមាគមសមាហរណកម្ម អាមេរិកឡាទីន
Launching Costs ថ្លៃចាប់ផ្តើមរកស៊ី
Launching Party ភាគី ឬក្រុមចាប់ផ្តើម
Laundering ការលាងលុយកខ្វក់
Law and Regulation ច្បាប់ និងបទបញ្ញត្តិ

Law of Contract ច្បាប់កិច្ចសន្យា

Law of Supply and Demand ច្បាប់ការផ្គត់ផ្គង់ និងតំរូវការ

Lawful Trade ពាណិជ្ជកម្មស្របច្បាប់

Least Developing Country (LDC) ប្រទេសដែលអភិវឌ្ឍន៍តិចបំផុត

Legal Aid of Cambodia (LAC) ជំនួយផ្នែកច្បាប់កម្ពុជា

Legal Capital មូលនិធិស្របច្បាប់

Legal Claim ការទាមទារស្របច្បាប់

Legal Currency រូបិយប័ណ្ណស្របច្បាប់

Legal Decision ការសំរេចតាមច្បាប់

Legal Monopoly សិទ្ធិផ្តាច់មុខស្របច្បាប់

Legal Ownership កម្មសិទ្ធិស្របច្បាប់

Legislative Structure រចនាសម្ព័ន្ធនីតិបញ្ញត្តិ

Legitimacy ភាពមានគតិយុត្តិ, ភាពស្របច្បាប់

Lending Procedures នីតិវិធីអោយខ្ចីប្រាក់

Less Developed Areas (LDAs) តំបន់មានការអភិវឌ្ឍន៍តិច

Less-Developed Countries (LDCs) ប្រទេសមានការអភិវឌ្ឍន៍តិចតួច

Letter of Allotment ប័ណ្ណភាគហ៊ុន

Letter of Attorney លិខិតផ្ទេរសិទ្ធិ

Letter of Credit (LC) លិខិតឥណទាន សារឥណទាន

Leveraged Buyout (LBO) ការទិញយកក្រុមហ៊ុនតាមរយៈខ្ចីបុលគេមកទិញ

Liaison Office ការិយាល័យទំនាក់ទំនង

Liberalization of Trade សេរីភាវូបនីយកម្មពាណិជ្ជកម្ម

Liberalize Trade in Services (LTS)
ការធ្វើពាណិជ្ជកម្មដោយសេរីលើវិស័យ សេវាកម្ម

Licensed Technology បច្ចេកវិទ្យាដែលមានអាជ្ញាប័ណ្ណ

Lien of Cargo សិទ្ធិយកទ្រព្យរបស់កូនបំណុលក្នុងការផ្ទុកទំនិញ

Lien of Goods សិទ្ធិយកទ្រព្យរបស់កូនបំណុលក្នុងការផ្ទុកទំនិញ

Limited Liability Company ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត

Limited Market ទីផ្សារដែលបរិមាណទំនិញមានកំរិត

Limited Partner ដៃគូចូលហ៊ុនមានកំរិត (ក្នុងការទទួលខុសត្រូវមានគំនិត)

Linkage Stream Programme (LSP) កម្មវិធីផ្លូវទំនាក់ទំនង

Linkage ការភ្ជាប់ទំនាក់ទំនង

Liquid Investment ការវិនិយោគជាសាច់ប្រាក់

Liquidation of Debt ការជំរះបញ្ជីបំណុល

Liquidity Preference (LP)
ការចូលចិត្តរបស់ដែលអាចផ្លាស់ប្តូរជាប្រាក់បានដោយឆាប់រហ័ស

Living Cost ថ្លៃនៃការរស់នៅ (ចំណាយលើជីវភាព)

Loan at Call ឥណទានគ្មានកាលកំណត់

Loan Disbursement ប្រាក់កម្ចីដែលបានដកប្រើប្រាស់

Local Labour ពលកម្មក្នុងប្រទេស

Local Rescue Coordination Centre (LRCC)
មជ្ឈមណ្ឌលសំរបសំរួលកិច្ច ជួយសង្គ្រោះ

Locally Recruited Staff បុគ្គលិកដែលរើសនៅនឹងកន្លែង

London ASEAN Committee (LAC) គណៈកម្មាធិការឡុនដុន អាស៊ាន

Long Lease ការជួលរយៈពេលវែង

Long Term Investment ការវិនិយោគរយៈពេលវែង

Long Term Planning

ផែនការរយៈពេលវែង គឺជាការកសាង និងអនុវត្តផែនការសំរាប់អភិវឌ្ឍន៍- សេដ្ឋកិច្ចជាតិ ឬវិស័យនីមួយៗរបស់សេដ្ឋកិច្ចសំរាប់រយៈ ពេលច្រើនឆ្នាំ (៥ឆ្នាំ ឬច្រើនជាង)។ ផ្តើមចេញពីការវិភាគ ស្ថានភាពសេដ្ឋកិច្ច និងទំនាក់ទំនងក្នុងជីវភាពសង្គមពិត។ ផែនការរយៈពេលវែង បង្ហាញឡើងនូវគំរិតនយោបាយ សេដ្ឋកិច្ចនៃការអភិវឌ្ឍន៍ ប្រទេសទៅអនាគត និងកំណត់មាគ៌ា និងមធ្យោបាយដែលមាន ប្រសិទ្ធិភាព និងសក្តិសិទ្ធិជាទីបំផុតក្នុងការអនុវត្តន៍ផែនការនោះ។

Long Term Vision ទស្សនៈយូរអង្វែង

Long Term/Short Term Loan កម្ចីរយៈពេលវែង /កម្ចីរយៈពេលខ្លី

Long-Run Aggregate Supply (LRAS) ការផ្គត់ផ្គង់សរុបដំណើរការវែង

Long-Run Average Cost (LRAC) ថ្លៃដើមមធ្យមដំណើរការវែង

Long-Run Equilibrium

សមតាមរយៈពេលវែង ប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវការចាំបាច់នូវសមតារយៈពេលវែង ដើម្បីធានានូវនិរន្តរភាព នៃការអភិវឌ្ឍន៍។ ដើម្បីសំរេចបាននូវកិច្ចការនេះ ទ្រឹស្តីកំណើនថ្មី បានបង្ហាញឡើងវិញនូវសារៈប្រយោជន៍ នៃតួនាទីរបស់រដ្ឋក្នុងការជំរុញ កំណើន និងការរក្សាសមតារយៈពេលវែង តាមរយៈការ អនុវត្តន៍ យុទ្ធសាស្រ្ត និងគោលនយោបាយផ្លាស់ប្តូររចនាសម្ព័ន្ធ ការតំរង់ទិសដៅ និងការបែកចែងធនធានឡើងវិញ ព្រមទាំងការជំរុញ និងការលើកទឹកចិត្ត វិនិយោគឯកជន នៅតាមបណ្តាផ្នែកនានា នៃប្រព័ន្ធសេដ្ឋកិច្ចជាតិ ដែលជាអតិភាពនៃការអភិវឌ្ឍន៍ សំរាប់រយៈពេលវែង។

Long-Run Industry Supply (LRS) ការផ្គត់ផ្គង់ឧស្សាហកម្មដំណើរការវែង

Long-Term Capital Investment ការវិនិយោគរយៈពេលវែង

Low Income People ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប

Lowering of Prices បញ្ចុះថ្លៃ

Loyal Body និតិបុគ្គល

Loyal Entity និតិអង្គភាព

Lutheran World Service (LWS) អង្គការសេវាពិភពលោកឡូតឺរ៉ែន

Luxury Goods

ទំនិញប្រណិត ជាទ្រព្យ សេចក្តីត្រូវការ គឺជាគន្លឹះសំរាប់ជំរុញដំណើរការផលិតកម្ម។ ប៉ុន្តែ នៅក្នុងល័ក្ខខ័ណ្ឌប្រទេសក្រីក្រ សេចក្តីត្រូវការទៅលើទំនិញប្រណិត និង ចំណង់រស់នៅរបៀបអ្នកហ៊ុហារ មិនទាន់ទៅជាកត្តាសំរាប់ធានានូវការកើតឡើងលើមូលដ្ឋានផលិតកម្មមួយ ដែលប្រទេសក្រីក្រ មិនទាន់មាន ហើយមិនអាចឈានទៅដល់ក្នុងពេលឆាប់ៗ បានឡើយ។ ដើម្បីផលិតបាននូវបណ្តាទំនិញប្រណិត ដូចនៅបណ្តាប្រទេសឧស្សាហកម្មជឿនលឿនប្រទេសក្រីក្រ ត្រូវការនូវមូលដ្ឋានខាងផ្នែកបច្ចេកទេស បច្ចេកវិទ្យា ចំណេះដឹង និងអ្វីៗផ្សេងទៀតជាច្រើន ។

## M

Macro-Economic Equilibrium គុល្យភាពម៉ាក្រូសេដ្ឋកិច្ច

Macro-Economic Policy គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

Macro-Economic Stabilization ស្ថិរភាវូបនីយកម្មម៉ាក្រូសេដ្ឋកិច្ច

Maintain Regional Macro Economic and Financial (MRMEF)
ការថែរក្សាម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងតំបន់

Maintain Regional Macro Economic and Financial Stability (MRMFS)
ការថែរក្សាម៉ាក្រូសេដ្ឋកិច្ចក្នុងតំបន់ និង ស្ថេរភាពហិរញ្ញវត្ថុ

Majority Decision ការសំរេចចិត្តតាមសំលេងភាគច្រើន

Malaysian Industrial Development Authority (MIDA)
អាជ្ញាធរអភិវឌ្ឍន៍ ឧស្សាហកម្មម៉ាឡេស៊ី

Management Committee (MC) គណៈកម្មាធិការគ្រប់គ្រង

Management Techniques បច្ចេកទេសគ្រប់គ្រង

Management Training ការបណ្តុះបណ្តាល និង គ្រប់គ្រង

Manila Action Plan for APEC (MAPA)
ផែនការសកម្មភាពសំរាប់អេប៉ិច នៅទីក្រុងម៉ានីល

Manpower Forecasting ការព្យាករណ៍កំលាំងពលកម្ម

Manpower Shortage ការខ្វះកំលាំងពលកម្ម

Manufacturer's Recommended Price
ថ្លៃលក់រាយកំណត់ដោយផលិតករ- ឧស្សាហករ

Manufacturing Cost ថ្លៃដើមផលិតកម្ម

MAPHILINDO កិច្ចព្រមព្រៀងរវាងម៉ាឡេស៊ី ហ្វីលីពីន និងឥណ្ឌូណេស៊ី

Margin of Preference (MOP) ដែននៃការអនុគ្រោះពន្ធ (នៅក្នុង PTA)

Marginal Cost (MC) ថ្លៃដើមកម្រិតទុកអោយ

Marginal Efficiency of Capital (MEC) ប្រសិទ្ធិភាពដើមទុនកម្រិតទុកអោយ

Marginal Efficiency of Investment (MEI) ប្រសិទ្ធិភាពនៃវិនិយោគកម្រិតទុកអោយ

Marginal Physical Product (MPP) ផលិតផលជាក់ស្តែងកម្រិតទុកអោយ

Marginal Product (MP) ផលិតផលកម្រិតទុកអោយ

Marginal Propensity to Consume និស្ស័យកម្រិតទុកអោយដើម្បីប្រើប្រាស់

Marginal Rate of Substitution (MRS) អត្រាជំនួសកម្រិតទុកអោយ

Marginal Revenue (MR) ផលចំណូលកម្រិតទុកអោយ

Marginal Revenue Product (MRP) ផលិតផលចំណូលកម្រិតទុកអោយ

Marine Fisheries Research Department (MFRD)
នាយកដ្ឋានស្រាវជ្រាវផ្នែក នេសាទសមុទ្រ

Maritime Law ច្បាប់នាវាចរណ៍

Maritime Trade ពាណិជ្ជកម្មតាមផ្លូវសមុទ្រ

Market Access ការឆ្ពោះទៅរកទីផ្សារ

Market Forecast ការព្យាករណ៍ទីផ្សារ

Market leader ក្រុមហ៊ុនដែលក្តាប់ទីផ្សារ

Market Opportunities កាលានុវត្តភាពនៃទីផ្សារ

Market Practice ទំលាប់ទីផ្សារ

Marketing Agreement កិច្ចព្រមព្រៀងលក់ទំនិញ

Market-Regulated Economy សេដ្ឋកិច្ចធ្វើនិយតកម្មដោយទីផ្សារ

Marking Requirements ការតំរូវអោយមានផ្លាកសញ្ញ

Mass Production ផលិតកម្មទ្រង់ទ្រាយធំ

Mass Unemployment ភាពគ្មានការងារធ្វើទ្រង់ទ្រាយធំ

Master Budget ថវិការគោល

Master of Management (MM) អនុបណ្ឌិតខាងគ្រប់គ្រង

Master Plan on Natural Gas Development and Utilization
ប្លង់មេស្តីពីការប្រើប្រាស់និងការអភិវឌ្ឍន៍ឧស្ម័នធម្មជាតិ

Master Plan ប្លង់គោល

Mature Economy សេដ្ឋកិច្ចរីកចំរើនពេញបន្ទុក

Means of Conveyance មធ្យោបាយដឹកជញ្ជូន

Means of Production មធ្យោបាយផលិតកម្ម

Measurement of Profitability ការគណនាពីលទ្ធភាពចំណេញ

Mechanism and Structure of Free Market Economy
យន្តការ និង ការរចនា សម្ព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី គឺជាប្រព័ន្ធសេដ្ឋកិច្ចដែលឈរលើមូលដ្ឋានកម្មសិទ្ធិឯកជន និងសេរីភាពជ្រើសរើស ក្នុងការធ្វើអាជីវកម្មលើទីផ្សារ ។ ដោយភ្នាក់ងារសេដ្ឋកិច្ចឯកជនមានតួនាទីសំខាន់ និងកំណត់ក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិ រដ្ឋលូកដៃធ្វើអន្តរាគមន៍ក្នុងសកម្មភាពសេដ្ឋកិច្ចក្នុងក្របខ័ណ្ឌអប្បបរិមា និងភាគច្រើនប្រើនិយតករសេដ្ឋកិច្ចផ្សេងៗ ក្នុងនោះមានដូចជា: គោលនយោបាយសារពើពន្ធ ច្បាប់វិនិយោគ គោលនយោបាយ រូបិយវត្ថុ គោលនយោបាយឥណទាន ។ល។

Mechanism and Structure of National Economy
យន្តការ និងរចនាសម្ព័ន្ធ សេដ្ឋកិច្ចជាតិ គឺជាកំលាំងចលករ (driving force) ដែលអាចជំរុញអោយ សេដ្ឋកិច្ចជាតិមានការអភិវឌ្ឍន៍ទៅតាមជីវភាព (dynamism) មួយជាកំណត់ស្របទៅតាមតំរូវការនៃការចំរើនរបស់សង្គម ។

Mechanization of Farms យន្តតូបនីយកម្មកសិកម្ម

Mediation ការធ្វើជាអាជ្ញាកណ្តាល

Medical Association of Southeast Asian Nations (MASEAN)

សមាគមពេទ្យ របស់អាស៊ាន (MASEAN) ជាអង្គការក្រៅរដ្ឋាភិបាល អាស៊ាន បញ្ចូលជាផ្លូវការដោយគណៈកម្មការអចិន្ត្រៃយ៍លើកទី ១៤ របស់អាស៊ាន នាថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៨២)

Medium Sized Engineering Company ក្រុមហ៊ុនវិស្វកម្មធុនមធ្យម

Medium Term Financial Strategy (MTFS)

យុទ្ធសាស្ត្ររយៈពេលជាមធ្យមផ្នែកហិរញ្ញវត្ថុ

Medium-Term Programme of Action កម្មវិធីសកម្មភាពរយៈពេលមធ្យម

Meeting of ASEAN Tourism Ministers (M-ATM)

កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍អាស៊ាន

Mekong River Commission (MRC) គណៈកម្មាការទន្លេមេគង្គ

Member of European Parliament (MEP) សមាជិកសភាសហគមន៍អឺរ៉ុប

Memo សារខ្លី, កំណត់ហេតុរំលឹក (Memorandum) អនុស្សរណៈ

Memorandum of Association អនុស្សរណៈនៃសមាគម

Memorandum of Understanding (MOU) អនុស្សរណៈនៃការព្រមព្រៀង

Mercado Comun de Cono Sur (MERCOSUR)

ក្រុមសេដ្ឋកិច្ចនៅអាមេរិកឡាទីន រួមមាន ប្រេស៊ីល អាហ្សង់ទីន ប៉ារ៉ាខ្វៃ និង អ៊ូរ៉ាខ្វៃ

Mercantile Country ប្រទេសមានចំណូលដោយសារការធ្វើពាណិជ្ជកម្ម

Merchant Law ច្បាប់ពាណិជ្ជលកម្ម

Micro-Business Enterprise (MBE) សហគ្រាសពាណិជ្ជកម្មតូចតាច

Micro-Investment វិនិយោគតូចតាច

Microwave Landing System (MLS) ប្រព័ន្ធចុះចតដោយប្រើរលកធាតុអាកាស មីក្រូ

Military and Civil Defense Assets (MCDA)
ទ្រព្យសម្បត្តិសំរាប់ការពាររបស់យោធានិងជនស៊ីវិល

Minimum Efficient Scale (MES) មាត្រដ្ឋានប្រសិទ្ធិភាពអប្បរមា

Minimum Lending Rate (MLR) អត្រាអោយខ្ចីអប្បរមា

Ministerial Conference for Economic Development in Southeast Asia (MCEDSEA)
សន្និសីទថ្នាក់រដ្ឋមន្ត្រីសំរាប់ការអភិវឌ្ឍន៍ សេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍

Ministerial Understanding (MU) ការព្រមព្រៀងថ្នាក់រដ្ឋមន្ត្រី

Ministers of Education and Those Responsible for Economic Planning in Asia and the Pacific (MINEDAP)
រដ្ឋមន្ត្រីអប់រំ និង អ្នកទទួលខុសត្រូវលើការរៀបចំផែនការសេដ្ឋកិច្ច និង ប៉ាស៊ីហ្វិក

Ministry of Commerce (MOC) ក្រសួងពាណិជ្ជកម្ម

Ministry of Economic and Finance (MOEF) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

Ministry of Foreign Affairs and International Cooperation (MOFA)
ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

Ministry of International Trade and Industry (MITI)
ក្រសួងពាណិជ្ជកម្មអន្តរជាតិ និង ឧស្សាហកម្ម

Ministry of Investment/ Investment Coordinating Board (BKPM)
ក្រសួងវិនិយោគទុន ឬក្រុមប្រឹក្សាសំរបសំរួលការវិនិយោគទុន

Ministry of Posts and Telecommunication (MPT)
ក្រសួងប្រៃសណីនិងទូរគមនាគមន៍

Minority Shareholder
ម្ចាស់ក្រុមហ៊ុនភាគតិច អ្នកចូលរួមមានភាគហ៊ុនតិចជាង ពាក់កណ្តាលនៃភាគហ៊ុនសរុប

Mobilization of Private Savings ការកៀងគរការសន្សំឯកជន

Modality of Investment ទំរង់ការនៃការវិនិយោគ

Monetarization of the Deficit រូបិយវត្ថុនីយកម្មនៃឱនភាព

Monetary Capital

មូលធនរូបិយប័ណ្ណ ជាតំលៃរូបិវត្ថុ

ដែលជាសមាសភាពរួមផ្សំរបស់មូលនិធិ បច្ចេកទេស។

តាមទ្រឹស្តីមូលនិធិរូបិយវត្ថុ ស្មើទៅនឹងតំលៃ គណនីនៃទ្រព្យសកម្ម

ដែលចាំបាច់សំរាប់ដំណើរការ សហគ្រាសមួយ។

Monetary Confidence តាមជំនឿ ឬការទុកចិត្តលើរូបិយវត្ថុ

Monetary Crisis

វិបត្តិរូបិយវត្ថុ អតុល្យភាពការទូទាត់យ៉ាងធ្ងន់ធ្ងរ នៃប្រព័ន្ធហិរញ្ញវត្ថុ

ក្នុងប្រទេស និងទំនាក់ទំនងហិរញ្ញវត្ថុអន្តរជាតិទាំងអស់ ។

វិបត្តិនេះមានឥទ្ធិពលយ៉ាងខ្លាំងលើសេដ្ឋកិច្ច បង្កើតដោយ

មានទំនាស់ក្នុងសង្គម និង បណ្តាលអោយមានបដិវាទកម្ម

រវាងប្រទេសនឹងប្រទេស។ វិបត្តិរូបិយវត្ថុមានន័យពីរយ៉ាង

១. ជាតុភ្ជួតភ្ជាប់នៃវិបត្តិសេដ្ឋកិច្ចទូទៅ (វិបត្តិរូបិយវត្ថុទូទៅ)

២. វិបត្តិរូបិយវត្ថុជាវដ្តនៃស្ថានភាពនៃរូបិយវត្ថុមួយចំនួន

ប្រសិនបើធៀបទៅនឹងវិបត្តិសេដ្ឋកិច្ចហូរហែរ (វិបត្តិរូបិយវត្ថុ

ដោយផ្នែក) ។

Monetary Policy គោលនយោបាយរូបិយវត្ថុ

Money Market Mutual Fund (MMMF) សង្គហធនទីផ្សាររូបិយវត្ថុ

Monitoring Information System (MIS) ប្រព័ន្ធពត៌មានគ្រប់គ្រង

Monopolistic Measures វិធានការដាច់មុខ

Most Favored Nation (MFN)

សិទ្ធិក្នុងការទទួលលក្ខខណ្ឌអនុគ្រោះខ្ពស់របស់

ប្រទេសនៅក្នុងទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ សិទ្ធិនេះ

ត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ ដែលពិនិត្យលើលទ្ធភាពផ្តល់នូវ រាល់សិទ្ធិឧត្តមភាព និង ការបន្ធូរបន្ថយផ្សេងៗក្នុងផ្នែកពន្ធគយ ដែលនឹងត្រូវយកមក ប្រើប្រាស់សំរាប់ជាផលប្រយោជន៍ដល់ភាគីទី៣ ។ សិទ្ធិក្នុង ការទទួលនូវលក្ខខណ្ឌអនុគ្រោះខ្ពស់នេះ គឺជាគោលការណ៍ មួយក្នុងបណ្តាគោលការណ៍សំខាន់ទាំងឡាយ ដែលជាមូលដ្ឋាននៃកិច្ចប្រមព្រៀងទូទៅ ស្តីពីពន្ធគយ និង ពាណិជ្ជកម្ម។ គួរកត់សំគាល់ថា ប្រព័ន្ធអនុគ្រោះផ្នែកពាណិជ្ជកម្មក្រៅ ប្រទេសនេះចាប់ផ្តើមអនុវត្តចាប់ពីឆ្នាំ ១៩៧០។ ក៏ប៉ុន្តែ ប្រទេសកម្ពុជាមានការរអាក់រអួលជាច្រើន ក្នុងការទទួលរបប អនុគ្រោះនេះដោយសារស្ថានភាពអសន្តិសុខ និងរបបនយោបាយ។ ថ្មីៗនេះ ប្រទេសកម្ពុជាទើបបានទទួលការអនុគ្រោះ ទាំងនេះឡើងវិញ ហើយបង្កលទ្ធភាពងាយស្រួលជាច្រើន ដល់កម្ពុជា ក្នុងការអភិវឌ្ឍន៍វិស័យ ពាណិជ្ជកម្ម និងឧស្សាហកម្មផ្សេងៗ។

Most Favored National Clause

កិច្ចសន្យាស្តីពីការអនុគ្រោះបំផុតផ្នែក ពាណិជ្ជកម្ម

Multidimensional Process

ដំណើរការពហុមាត្រដ្ឋាន ការអភិវឌ្ឍន៍ គឺជាដំណើរការពហុមាត្រដ្ឋានដែលរួម បញ្ចូលនូវការផ្លាស់ប្តូរ ទាំងខាងផ្នែកបរិមាណ និងគុណភាព ការអភិវឌ្ឍន៍ គឺជាការផ្លាស់ប្តូររចនាសម្ព័ន្ធសង្គម រចនាសម្ព័ន្ធសេដ្ឋកិច្ច រចនាសម្ព័ន្ធ និងប្រព័ន្ធនយោបាយ ស្ថាប័នសង្គម និង រដ្ឋបាល ឥរិយាបថ និងផ្នត់គំនិតរបស់ប្រជាជនសមត្ថភាពការងារ សុខមាលភាព

និងជីវភាពរបស់ប្រជាជន។ ក្នុងន័យនេះ ការអភិវឌ្ឍន៍ត្រូវបានវាយតំលៃ តាម មាត្រដ្ឋានសំខាន់ៗដូចជា: មាត្រដ្ឋានសេដ្ឋកិច្ច មាត្រដ្ឋាន នយោបាយ មាត្រដ្ឋានសង្គម មាត្រដ្ឋានធនធានមនុស្ស និង មាត្រដ្ឋានបរិស្ថាន ។ល។

Multilateral Agreement កិច្ចព្រមព្រៀងពហុភាគី

Multilateral Assistance Initiative/Philippines Assistance Programme (MAI/PAP)
គំនិតផ្តួចផ្តើមជំនួយពហុភាគី /កម្មវិធីជំនួយ ហ្វីលីពីន

Multilateral Assistance ជំនួយពហុភាគី

Multilateral Diplomacy ការទូតពហុភាគី

Multilateral Investment Guarantee Agency (MIGA)
ទីភ្នាក់ងារទទួលខុសត្រូវការវិនិយោគទុនចំរុះ

Multilateral Trade Negotiations (MTN) ការចរចាពហុភាគីផ្នែកពាណិជ្ជកម្ម

Multilateral Trade ពាណិជ្ជកម្មពហុភាគី

Multimedia Super Corridor (MSC) មហារបៀងប្រព័ន្ធផ្សព្វផ្សាយ

Multimodel Transport and New Information Technology (MT-NIT)
វិធីដឹកជញ្ជូនពហុបែប និង បច្ចេកវិទ្យាថ្មីនៃពត៌មាន

Multi-National Corporations (MNCs)
សាជីវកម្មដែលមានសាខានៅច្រើនប្រទេស សាជីវកម្មពហុជាតិ

Multi-National Enterprises (MNEs) សហគ្រាសដែលមានសាខានៅច្រើនប្រទេស

Multiple Entry Visa ទិដ្ឋការចូលក្នុងប្រទេសបានច្រើនលើក

Multiple Shop Undertaking ក្រុមហ៊ុនដែលមានសាខាច្រើន

Multual Consultation ការពិគ្រោះយោបល់គ្នាទៅវិញទៅមក

